

■ កាកអំពៅក្លាយទៅជាចានក្រដាស <ទំព័រ៖ ៣

■ ឱជេ ណាណា ជំរុញឱ្យក្មេងស្រីទាំងអស់មិនត្រូវបោះបង់ និងត្រូវក្លាហានពុះពារបន្តក្ដីស្រមៃ <ទំព័រ៖ ០៦



កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១៣

# អ្នកនាំសារ the messenger

ខែ មិថុនា | ឆ្នាំ ២០២៣ | លេខទី ១៥៧

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

JUNE, 2023 | #157



## ឈាមមរណសាក្សី ជាគ្រាប់ពូជនៃជំនឿ

រឿងពេញទំព័រ-១២

■ ក្រុងថ្មីមួយ កំពុងតែលេចរូបរាងឡើងនៅកណ្ដាលព្រៃនៃឧទ្យានជាតិបុទុមសាគរ ទំព័រ-០៨



■ ដំណឹងល្អបានឮដល់ជនជាតិដើមភាគតិចនៅខេត្តរតនគិរី ទំព័រ-១៧



■ លោក អេនរីគេះ ២៣ឆ្នាំជាអភិបាលអំណរសប្បាយមានច្រើន ទំព័រ-១៨



# កុំភ្លេចទៅបោះឆ្នោត ជ្រើសរើសមេដឹកនាំប្រទេសយើង

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២៣ខាងមុខនេះ។ តាមសេចក្ដីប្រកាសរបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានឲ្យដឹងថា មានគណបក្សនយោបាយចំនួន១៨ បានចុះឈ្មោះត្រឹមត្រូវ ចូលរួមបោះឆ្នោតក្នុងឆ្នាំ២០២៣នេះ។ ចំណែកគណបក្សភ្លើងទៀនមិនមានក្នុងបញ្ជីបោះឆ្នោតនោះទេ ដោយសារខកខានមិនបានបំពេញគ្រប់តាមលក្ខខ័ណ្ឌដែលច្បាប់បានតម្រូវ នៅពេលចុះបញ្ជីគណបក្សនយោបាយនៅ គ.ជ.ប។

បងប្អូនជាទីស្រឡាញ់ ការបោះឆ្នោតសំខាន់ណាស់ ដែលប្រជាពលរដ្ឋគ្រប់រូប ប្រើសិទ្ធិរបស់ខ្លួនជ្រើសរើសមេដឹកនាំដែលខ្លួនពេញចិត្ត ដោយយល់ថា លោកមានសមត្ថភាពដឹកនាំប្រទេសឲ្យរីកចម្រើន មានស្ថេរភាពនយោបាយល្អ មានសន្តិភាព មានសន្តិសុខ យកចិត្តទុកដាក់នឹងសុខមាលភាពរបស់ពលរដ្ឋ ។ល។

សម្រាប់បងប្អូនជាគ្រីស្តបរិស័ទ ការបោះឆ្នោតកាន់តែសំខាន់ថែមទៀត ព្រោះយើងបោះជ្រើសរើសអ្នកដឹកនាំ ដែលយកចិត្តទុកដាក់ចំពោះប្រជាជន បម្រើប្រជាជន និងប្រទេសជាតិយើងទាំងមូល។ តាមជំនឿ គ្រីស្តបរិស័ទ ម្នាក់ៗជាឧបករណ៍របស់ព្រះជាម្ចាស់ ដើម្បីជ្រើសរើសអ្នកណែនាំប្រទេស តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលយកចិត្តទុកដាក់យ៉ាងពិសេស ចំពោះសន្តិភាព ស្រឡាញ់ពលរដ្ឋពិតប្រាកដ បម្រើប្រទេសជាតិពិតៗ ដឹកនាំប្រទេសទៅកាន់ភាពសំបូរសប្បាយរុងរឿង។

បងប្អូនប្រាកដណាស់ គឺមានបទពិសោធ ធ្លាប់ចូលរួមបោះឆ្នោតរួចមកហើយ បានប្រើប្រាស់សិទ្ធិរបស់ខ្លួនយ៉ាងពិតប្រាកដ។ បងប្អូនមួយចំនួនក៏បានរស់នៅឆ្លងកាត់វិថីជីវិតតាមរបត់នយោបាយនានារបស់ប្រទេសកម្ពុជា ដែលបានឆ្លងកាត់ការស្រេកឃ្លាន ភាពអយុត្តិធម៌ ការឈឺចាប់ខ្លោចផ្សារ អសន្តិសុខ វាលពិឃាត សង្គ្រាមបង្ហូរឈាមខ្មែរនិងខ្មែរ មនុស្សជាច្រើនបានស្លាប់ និរាសព្រាត់ប្រាស់ បែកបាកគ្រួសារ។ល។

ហេតុដូច្នេះលិទ្ធិប្រជាធិបតេយ្យ ជាព្រះអំណោយទានពីព្រះជាម្ចាស់។ ការទៅបោះឆ្នោតសំខាន់ណាស់ ដើម្បីជ្រើសរើសមេដឹកនាំជាតិប្រកបដោយ ចរិយាសម្បត្តិល្អ គុណធម៌ សុចរិតភាព គោរពសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិដែលជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ការប្ដេជ្ញាចិត្តខ្ពស់ ទស្សនៈគោលនយោបាយ និងសេដ្ឋកិច្ចច្បាស់លាស់។ យើងជ្រើសរើមេដឹកនាំដែលមានសមត្ថភាព មានចំណេះដឹងនិងជំនាញគ្រប់គ្រាន់ ប្រព័ន្ធគណនេយ្យភាពត្រឹមត្រូវនិងមានតម្លាភាព។ ជាមេដឹកនាំ មានចិត្តមេត្តា ស្រឡាញ់ពលរដ្ឋ បម្រើពលរដ្ឋ គោរពច្បាប់ ស្អប់ខ្ពើមអំពើពុករលួយ និងភាពស្មើគ្នាសម្រាប់ពលរដ្ឋគ្រប់រូប។

សម្រាប់កម្ពុជា សន្តិភាពសំខាន់ណាស់! សូមកុំភ្លេចទៅបោះឆ្នោតគ្រប់ៗគ្នា៕




CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្ដីប្រកាសលេខ៖ លេខចុះបញ្ជី២០២២៖ ១២៧៩|២២ផត.ប្រ
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Contact: (855) 17 726 060
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# កាកអំពៅក្លាយទៅជាចានក្រដាស

*អត្ថបទ៖ សុផានិត*

ក្រុមហ៊ុន MG Pacific Company Limited បានផ្គត់ផ្គង់ដល់ទីផ្សារក្នុងស្រុក នូវចានក្រដាសក្នុងតម្លៃមួយដ៏ល្អ ដើម្បីប្រើប្រាស់ប្រចាំថ្ងៃ ជាមួយនឹងការត្អូញត្អែរពីកង្វះខាតនៃការគាំទ្រសម្រាប់ក្រុមហ៊ុនតូចរបស់លោក។



នេះជាការលើកឡើងរបស់ស្ថាបនិក និងនាយកគ្រប់គ្រងក្រុមហ៊ុន MG Pacific Company Limited លោក តាំង សុជាតិ ដែលលោកជាយុវជនខ្មែរម្នាក់ ដែលបានចំណាយពេលរហូតដល់ទៅ ៣ ឆ្នាំដើម្បីបង្កើតឧបករណ៍កែច្នៃ សម្រាប់កែច្នៃចានក្រដាសពីកាកសំណល់អំពៅក្នុងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយការប្រើប្រាស់ផលិតផលប្លាស្ទិក។

លោក តាំង សុជាតិ បាននិយាយថា ៖ «កិច្ចខិតខំប្រឹងប្រែងរបស់ខ្ញុំ គឺចង់បង្ហាញអ្នកប្រើប្រាស់នូវអត្ថប្រយោជន៍នៃការកែច្នៃកាកសំណល់ និងជាសញ្ញាមួយក្នុងការកាត់បន្ថយកម្រិតនៃការបំពុល។ សិប្បកម្មយើងបានបង្កើតផលិតផលក្នុងស្រុក និងការងារបន្ថែមទៀតសម្រាប់ប្រជាជន»។

លោក តាំង សុជាតិ ក៏បានលើកឡើងទៀតថា លោកបង្កើតចានផលិតពីកាកអំពៅនេះ ព្រោះចង់ផលិតរបស់ប្រើប្រាស់ចេញពីរបស់ដែលប្រជាជនខ្មែរបានប្រើ ហើយបោះចោលទាំងវាអាចយកមកធ្វើការកែឆ្នៃបាន។

លោកបានបញ្ជាក់ថា៖«ជាធម្មតាអ្នកលក់ទឹកអំពៅតែងតែយកសំណល់កាកអំពៅទៅបោះចោលតាមវាលគ្រប់ទីកន្លែង ឬយកទៅដុតចោល។ សម្រាប់សិប្បកម្មរបស់ខ្ញុំបានយកសំណល់កាកអំពៅមកឆ្នៃទៅជាក្រដាស ដែលយើងហៅថាក្រដាស់អំពៅ រួចយកវាមកជំនួសការប្រើប្រាស់ប្លាស្ទិក»។

ស្ថាបនិក និងនាយកគ្រប់គ្រងក្រុមហ៊ុន MG Pacific Company Limited រូបនេះ បានប្រាប់ឱ្យដឹងទៀតថា នៅកម្ពុជា ការប្រើប្រាស់ប្លាស្ទិក មានការពេញនិយមណាស់ សម្រាប់ចានធ្វើពីស្នោរ វាមិនងាយរលាយទៅជាដីនោះទេ វាត្រូវការពេលយ៉ាងហោចណាស់ ៧០០ ទៅ៨០០ឆ្នាំ។

លោកថា ៖ «ដូច្នេះទើបយើងកែឆ្នៃចានផលិតពីសំណល់កាកអំពៅ ដែលគេតែងតែយកទៅបោះចោលនោះ មកឱ្យប្រជាជនប្រើប្រាស់ជំនួសប្លាស្ទិកទាំងនោះ ដើម្បីជាផ្នែកមួយជួយដល់បរិស្ថាន។ លើសពីនេះសិប្បកម្មរបស់ខ្ញុំបានបង្កើតផលិតផលក្នុងស្រុក និងបង្កើតការងារឱ្យប្រជាជនមានចំណូលផងដែរ តាមរយៈការកែឆ្នៃមួយនេះ»។

លោក តាំង សុជាតិ បានបន្តថា សម្រាប់បច្ចេកទេសវិញ លោកបានធ្វើការកែលម្អមកពីបច្ចេកទេសនានារបស់ប្រជាជនខ្មែរផ្ទាល់តែម្តង។



លោក តាំង សុជាតិ បានបញ្ជាក់ថា ៖ «ផលលំបាកដែលលោកកំពុងជួបនោះ គឺផលិតផលរបស់លោកមានតម្លៃថ្លៃ ព្រោះការផលិតយើងបានចំនួនតិច និងចំណាយច្រើន ដូច្នេះថ្លៃដើមក្នុងការផលិតរបស់យើងវាខ្ពស់»។

លោកថា ៖ «តែប្រសិនជាអ្នកប្រើប្រាស់ឲ្យតម្លៃទៅលើគុណតម្លៃ ទៅលើការខិតខំនោះ តម្លៃផលិតផលមួយនេះនៅតិចណាស់ ដូច្នេះខ្ញុំសូមស្នើឱ្យប្រជាជនកម្ពុជាជួយបន្តការគាំទ្រសិន ព្រោះថាប្រសិនជាយើងមិនបន្តការគាំទ្រនៅពេលនេះ នោះផលិតផលមួយនេះគ្មានថ្ងៃណាមានតម្លៃថោកនោះទេ»៕

ជាមួយគ្នានេះដែរ លោក សុផាន់ ដែលជាអ្នកបច្ចេកទេសនៅក្រុមហ៊ុន ក៏បានប្រាប់ដែរថាពួកគេបាននាំយកនូវឧបករណ៍ចាស់ៗពីផ្សារ និងយានដ្ឋានជួសជុលរថយន្តដើម្បីកែច្នៃប្រើប្រាស់ឡើងវិញក្នុងការបង្កើតជាឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងរោងចក្ររបស់ពួកគេ៕





# សត្វព្រៃដែលជិតផុតពូជមួយចំនួនត្រូវបានរកឃើញបន្ថែម










*អត្ថបទ៖ អមរិទ្ធិ ដានុត*

ក្រសួងបរិស្ថានបានប្រកាសឱ្យដឹងថា ចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ក្រុមការងារអនុសមាសភាគ ១.២ នៃគម្រោង «និរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិ កម្ពុជា» បានតាមដាន និងរកឃើញវត្តមានប្រភេទសត្វព្រៃសំខាន់ៗដែលជិតផុតពូជមួយចំនួនផងដែរ។

ការសិក្សា និងតាមដានេះ មានការសហការជាមួយនាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប នៃអគ្គនាយកដ្ឋានតំបន់ ការពារធម្មជាតិ មន្ទីរបរិស្ថានខេត្តពោធិ៍សាត់ និងមន្ត្រីឧទ្យានុរក្ស បានចុះដោះប្រមូលម៉ាស៊ីនថតស្វ័យប្រវត្តិដែលបានដាក់ សិក្សារយៈពេលជាង ៣ខែ ដើម្បីតាមដានវត្តមានប្រភេទសត្វព្រៃសំខាន់ៗដែលជាក្រុមប្រភេទជិតផុតពូជ (EN)។

ក្រុមប្រភេទកំពុងទទួលរងការគំរាមកំហែង (VU) និងក្រុមប្រភេទជិតទទួលរងការគំរាមកំហែង (NT) មានតំលៃអភិរក្សក្នុងតំបន់ និងជាសកលដែលត្រូវបានចុះក្នុងបញ្ជីក្រហម IUCN។

ក្រសួងបរិស្ថានបានឱ្យដឹងទៀតថា ម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ២០គ្រឿង ត្រូវបានដោះ ប្រមូលពីទីតាំងសិក្សាមួយចំនួនក្នុងដែនជម្រកសត្វព្រៃក្នុង ភូមិសាស្ត្រខេត្តពោធិ៍សាត់។

ប្រភពដដែលថា ជាលទ្ធផលជាបឋម ការសិក្សានេះបានរកឃើញ និងបញ្ជាក់ពីវត្តមានជាបន្តប្រភេទសត្វព្រៃចំនួន ៧ប្រភេទ ក្នុងនោះមាន ដូចជា៖ ដំរីអាស៊ី ខ្ទីង ខ្លាពពក ខ្លាឃ្មុំធំ ប្រើសស្បូវ ខ្ទីន ឆ្កែព្រៃ ក្ងោក ដែលត្រូវបានកត់ត្រា និងរាយការណ៍ក្នុងឆ្នាំ២០២០ ដោយគម្រោង CSLEP/MOE។

ដោយឡែក ប្រភេទសត្វព្រៃមានដាកម្រ (EN) និង(VU) ចំនួន ៣ប្រភេទផ្សេងទៀត ត្រូវបានកត់ត្រា និងបញ្ជាក់ពីវត្តមានបន្ថែមតាមយៈការសិក្សានេះ។ ប្រភេទសត្វព្រៃទាំងនេះរួមមាន៖ ពង្រូល ខ្លាលឿង មាស សត្វយំឬសត្វចាំត្រពាំង។



ក្រសួងបានបញ្ជាក់ថា ៖ «ការសិក្សានេះជាការសិក្សាត្រួតពិនិត្យ និងតាមដានពីវត្ត មានប្រភេទសត្វព្រៃសំខាន់ៗដែលមានតំលៃអភិរក្សក្នុងតំបន់ និងជាសកល ព្រមទាំងវាជាផ្នែកមួយនៃការអនុវត្តផែនការគ្រប់គ្រងដែនជម្រកសត្វព្រៃដែលទទួលការឯកភាពពីក្រសួងបរិស្ថាននៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២»។

បើតាមក្រសួងបរិស្ថាន ម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ២០គ្រឿង ត្រូវបានដោះ ប្រមូលពីទីតាំងសិក្សាមួយចំនួនក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រខេត្តពោធិ៍សាត់ ក្នុងនោះរួមមាន នៅចំណុច ដំណាក់ត្រប អូរល្ពង ស្ទឹងក្រហម ថ្មយ៉ន ថ្មធំ ខ្មោចចាម ខ្នងស្រល់ និងដំណាក់យានលន់បានដោយជោគជ័យ៕

# eCO បញ្ចើមុខម្ហូបឌីជីថល ដំបូងនៅកម្ពុជា

*ផល សុផានិត*

eCO ជាផ្លែតហ្វមដំបូងនៅកម្ពុជា ដែលបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២១ ដើម្បីធ្វើទំនើបកម្មម៉ឺនុយទៅជាឌីជីថលដើម្បីជំនួសមីនុយក្រដាស។ តាមរយៈ eCO នេះ មីនុយឌីជីថល (digital menu) ឬមីនុយវៃឆ្លាត (smart menu) នឹងអាចរួមចំណែកលើកមុខមាត់ប្រទេសជាតិ តាមរយៈគ្រប់តំបន់ ទាំងទីក្រុង និងជនបទ ក៏អាចប្រើប្រាស់បច្ចេកវិទ្យា។

ស្ថាបនិក eCO លោក ង៉ែត សុផាត ថា eCO ជាផ្លែតហ្វមសង្គមទីមួយនៅកម្ពុជាដែលផ្តោតសំខាន់លើការធ្វើទំនើបកម្មមីនុយឲ្យទៅជាឌីជីថល ដើម្បីជំនួសមីនុយក្រដាស។ នៅក្នុងខែកក្កដា ឆ្នាំ២០២២ eCO បានដាក់ដំណើរការសាកល្បងជាមួយហាងកាហ្វេ De Burlap Café នៅក្នុងសហគមន៍ចំការដូង។

លោក ង៉ែត សុផាត បានបន្តថា ៖ «ក្រុមហ៊ុនធំៗចំណាយលុយជាងខ្ទង់លានដុល្លារដើម្បីជួយជំរុញអាជីវកម្មគេ ចុះធ្វើម៉េចឲ្យអាជីវកម្មក្នុងសហគមន៍ដូចហាងកាហ្វេ អ្នកលក់លតឆា មីឆា តាមរទេះ ដែលអាចមានបច្ចេកវិទ្យាប្រើ ដើម្បីជួយមុខរបររបស់គាត់បាន។ តាមរយៈចំណេះដឹងផ្នែកបច្ចេកវិទ្យាដែលខ្ញុំមាន និងបទពិសោធន៍ដែលឆ្លងកាត់ក្នុងវិស័យនេះ ក៏សម្រេចចិត្តប្រើវាជាប្រយោជន៍សម្រាប់សហគមន៍»។

លោក ង៉ែត សុផាត បានបន្តទៀតថា ការបង្កើត eCO នេះឡើងក៏មានការចូលរួមពីស្ថាបនិកមួយរូបផ្សេងទៀត ដែលជាមិត្តភក្តិរបស់លោកផងដែរ។ ហើយផលលំបាក ដែលកើតពីការខ្វែងគំនិតគ្នាក៏មាន។ បន្ថែមពីនេះទៀតក៏មានបញ្ហាទៅលើផ្នែកហិរញ្ញវត្ថុ ខណៈពេលទំហំនៃការងារដែលមានបំណងធ្វើមានទំហំធំ ប៉ុន្តែថវិកាមានកម្រិត ក៏សម្រេចចិត្តធ្វើដោយផ្តោតលើផលិតផលមួយជាមុនសិន។ នៅពេលធ្វើដោយផ្តោតលើផលិតផលតែមួយ ធ្វើឱ្យសមិទ្ធិផលនៃការងារក៏តូច ដែលធ្វើឱ្យម្ចាស់អាជីវកម្ម មិនទុកចិត្ត បើទោះជាមានការផ្តល់ជូនដោយឥតគិតថ្លៃក៏ដោយ ប៉ុន្តែ ប៉ុន្តែលោក បានបន្តជួបម្ចាស់ហាងរៀងរាល់ថ្ងៃរហូតដល់មានអ្នកសាកល្បងប្រើផ្លែតហ្វមនេះ។

លោក ង៉ែត សុផាត បានបន្ថែមថា ម្ចាស់អាជីវកម្មដែលប្រើប្រាស់ផ្លែតហ្វម eCO នេះ មិនចាំបាច់ចំណាយច្រើនលើការបោះពុម្ពមីនុយ ថែមទាំងពេលចង់ដូរតម្លៃ ដូរឈ្មោះ និងថែម ឬដកមុខមីនុយ មិនចាំបាច់ត្រូវបោះពុម្ពម៉ឺនុយថ្មី។ លើសពីនេះទៀត ក្រោយដាក់ដំណើរការសាកល្បង ម្ចាស់អាជីវកម្មបានឱ្យដឹងថា ការលក់កើនឡើង៥ ទៅ៧ភាគរយ និងមុខម្ហូប ឬភេសជ្ជៈដែលភ្ញៀវមិនធ្លាប់កាម៉្មង់ ចាប់ផ្តើមមានអ្នកកាម៉្មង់។ ផ្លែតហ្វម eCO ក៏អាចឱ្យដឹងបានថា មុខម៉ឺនុយមួយណាដែលភ្ញៀវចាប់អារម្មណ៍តិច ឬច្រើន។




លោក ង៉ែត សុផាត បានបន្ថែមទៀតថា អតិថិជនដែលប្រើប្រាស់ការស្កេន QR Code នេះ មិនត្រូវការ ការដោនឡូតកម្មវិធីនោះឡើយ។ ហើយពួកគាត់ អាចចំណាយពេលដោយសេរីភាពក្នុងការមើលនិងជ្រើសរើសមុខម្ហូប ឬភេសជ្ជៈ ដែលខ្លួនពេញចិត្តដោយមិនមានអ្នករំខាន ឬក៏ត្រូវរអៀសចិត្តឡើយ។ បន្ថែមពីនេះទៀត អតិថិជនអាចរកបាននូវការប្រម៉ូសិនក្នុងហាងយ៉ាងងាយ និងអាចភ្ជាប់អ៊ីនធឺណឹត (wifi) ដោយមិនចាំបាច់រំខានបុគ្គលិកហាង។

លោក ង៉ែត សុផាត បានឱ្យដឹងទៀតថា eCO មិនត្រឹមតែជាផ្លែតហ្វម ដែលផ្តល់អត្ថប្រយោជន៍ និងភាពងាយស្រួលដល់ម្ចាស់អាជីវកម្ម និងអតិថិជនប៉ុណ្ណោះទេ ប៉ុន្តែផ្លែតហ្វម eCO ថែមទាំងមានសារៈសំខាន់សម្រាប់ប្រទេសកម្ពុជាថែមទៀតផង។ eCO អាចរួមចំណែកលើកមុខមាត់ប្រទេសកម្ពុជា តាមរយៈប្រើប្រាស់បច្ចេកវិទ្យាគ្រប់តំបន់ ទាំងនៅទីក្រុង និងជនបទ។

នៅក្នុងផ្លែតហ្វម eCO មានការប្រើប្រាស់ភាសារហូតដល់បីភាសា រួមមានភាសាខ្មែរ អង់គ្លេស និងភាសាចិន។ ហើយអតិថិជនដែលមកស្កេនeCOក្នុងហាង មិនមានគិតថ្លៃសេវាឡើយ។ចំណែកឯម្ចាស់ហាងដែលប្រើ eCO ត្រឹមមុខងារម៉ឺនុយ ក៏មិនមានការគិតថ្លៃសេវាដែរ។ ប៉ុន្តែប្រសិនបើមានការប្រើប្រាស់លើលពីម៉ឺនុយនេះ នឹងតម្រូវឲ្យបង់ប្រាក់១០០រៀលខ្មែរ ក្នុងមួយប្រតិបត្តិការ៕

# សហគមន៍ចំនួន៤៦ចុះកិច្ចសន្យាកសិកម្មជាមួយរោងម៉ាស៊ីនកិនស្រូវ



*អត្ថបទ៖ អមរិន្ទ ដានុត*

សហព័ន្ធស្រូវអង្ករកម្ពុជា បានចុះកិច្ចសន្យាកសិកម្មស្តីពីការផលិត និងផ្គត់ផ្គង់ស្រូវ ជាមួយនឹងរោងម៉ាស៊ីនកិនស្រូវ និងសហគមន៍ចំនួន៤៦ ក្នុងខេត្តកំពង់ធំ កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ ក្រោមអធិបតីភាពលោក ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

លោក ឌិត ទីណា បានលើកឡើងនាឱកាសនោះថា រាជរដ្ឋាភិបាលកម្ពុជាលើវិស័យកសិកម្ម ដែលគំនិតផ្តួចផ្តើមឱ្យមានកិច្ចសន្យាកសិកម្មនេះធ្វើឡើងដើម្បីរួមចំណែកដោះស្រាយបញ្ហាទីផ្សារសម្រាប់ប្រជាកសិករ។

លោកមានប្រសាសន៍ថា ៖ «ការចុះកិច្ចសន្យាកសិកម្ម ទាមទារឱ្យភាគីទាំងសងអស់ ទាំងខាងក្រុមហ៊ុននាំចេញ រោងម៉ាស៊ីនកិនស្រូវ និងសហគមន៍គោរពកិច្ចសន្យា និងស្មោះត្រង់ជាមួយគ្នា»។

ឆ្លៀតឱកាសនោះដែរ លោករដ្ឋមន្ត្រីក៏បានជំរុញឱ្យសហគមន៍ប្រើប្រាស់ពូជសុទ្ធ និងអនុវត្តបច្ចេកទេសឱ្យបានត្រឹមត្រូវ ដោយក្រសួងគ្រោងនឹងរៀបចំប្រព័ន្ធកសិកម្មថ្មី ដែលជួយកសាងសហគមន៍ឱ្យរឹងមាំ តាមរយៈការដាក់ចេញគោលនយោបាយមន្ត្រីបច្ចេកទេសកសិកម្មតាមឃុំ និងការគិតគូរក្នុងការជួយសហគមន៍ឱ្យរឹងមាំ គឺត្រូវធ្វើការរួមគ្នាប្រកបដោយតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវរបស់សហគមន៍។

កិច្ចសន្យាកសិកម្មនេះត្រូវបានរៀបចំឡើងដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហព័ន្ធស្រូវអង្ករកម្ពុជា ដែលមានការគាំទ្រពីនាយកដ្ឋានកសិឧស្សាហកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលសាលាខេត្តកំពង់ធំ និង ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់សហព័ន្ធស្រូវអង្ករកម្ពុជា បានឱ្យដឹងថា កិច្ចសន្យាកសិកម្មនេះ អនុវត្តន៍ដោយសហគមន៍ចំនួន ៤០ និងក្រុមផលិតចំនួន ៦ រួមខាំអនុស្សរណៈយោគយល់ចំនួន១ ជាមួយស្ថាប័នមីក្រូ ហិរញ្ញវត្ថុក្នុងការធានាការទូទាត់នៅពេលប្រមូល។

សហព័ន្ធស្រូវអង្ករបានបន្តថា កិច្ចសន្យាទាំង ៤៦ នេះ គ្របដណ្តប់លើផ្ទៃដីចំនួន ៦៦៩០ ហិកតា និងអនុវត្តន៍ដោយកសិករចំនួន ២ ២៣៦ គ្រួសារ នៅក្នុងស្រុកទាំង៧ គ្រប់ដណ្តប់លើប្រភេទពូជស្រូវ និងទទួលទិញស្រូវចំណីចំនួន ១៧ ៦៦៣ តោន។

ប្រភេទ ស្រូវទាំងនោះមានដូចជា៖ ស្រូវប្រភេទផ្ការំដួលមានចំនួន ៦២៣៣ តោន, ស្រូវសែនក្រអូប មានចំនួន ២ ៨៩០ តោន, ស្រូវប្រភេទអូអីមមានចំនួន ១ ៨៥០ តោ, ស្រូវគ្រាប់ខ្លីចំនួន ៦ ៦៩០ តោន និងកិច្ចសន្យាលើបន្លែតាមបរិមាណជាក់ស្តែងផងដែរ។

លោក ចាន់ សុឃាំង ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានលើកឡើងឱ្យដឹងថា ការរីកចម្រើនវឌ្ឍនាការរបស់វិស័យស្រូវអង្ករ កើតចេញពីគោលនយោបាយដឹកនាំដ៏ត្រឹមត្រូវ និងប្រកបដោយចក្ខុវិស័យច្បាស់លាស់របស់រាជរដ្ឋាភិបាល លើការជំរុញផលិតកម្ម និងការនាំចេញអង្ករ។

ចក្ខុវិស័យនេះ បានធ្វើឱ្យផលិតកម្មស្រូវកម្ពុជាមានអតិរេករហូតដល់ជិត ៦លានតោន ដែលផ្តល់លទ្ធភាពឱ្យកម្ពុជាអាចធ្វើការកិនកែច្នៃ និងការនាំចេញស្រូវទៅប្រទេសជិតខាងដែលជាក់ស្តែងរយៈពេល៥ខែ ដើមឆ្នាំ២០២៣ កម្ពុជាបានសម្រេចការនាំចេញអង្ករបាន ចំនួន ២៧៨ ១៨៤ តោន ដែលគិតជាទឹកប្រាក់បានប្រមាណជាជាង១៩១ លានដុល្លារសហរដ្ឋអាមេរិក។ ការនាំចេញស្រូវទៅកាន់ប្រទេសជិតខាងបានចំនួន២ ១៤២ ៤៨៣ តោន (ប្រមាណជា ១.៣៧ លានតោនអង្ករ) ដែលគិតជាទឹកប្រាក់ មានចំនួនជាង ៥៤៥ លានដុល្លារសហរដ្ឋអាមេរិក។

លោកបានបញ្ជាក់ថា ៖ «ជារួមការនាំចេញស្រូវ និងអង្ករនេះ គឺបានចំណូលប្រមាណជាជាង ៧៣៦ លានដុល្លារសហរដ្ឋអាមេរិកចូលក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា»។

ចំណែក លោក សុង សារ៉ន ប្រធានក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករ ក៏បានលើកឡើងពីការប្រឈមរបស់វិស័យ ស្រូវអង្ករក្នុងការផលិត កែច្នៃ នាំចេញ ជាមួយប្រទេសដែលផលិតស្រូវអង្ករដូចកម្ពុជាផងដែរគឺការប្រកួតប្រជែងលើថ្លៃដើម គុណភាព ចីរភាព ការច្នៃប្រឌិត និងការធ្វើពិពិធកម្មគោលដៅទីផ្សារ និងផលិតផល។

លោកបានបញ្ជាក់ថា ៖ «ការងារទាំងនេះ គឺចំបាច់ត្រូវ រៀបចំយុទ្ធសាស្ត្រផែនការសកម្មភាពដោះស្រាយហើយយុទ្ធសាស្ត្រដែលអាចដោះស្រាយ និងឆ្លើយតបមានប្រសិទ្ធភាព និងអាចទាញបានផលលឿននោះ គឺការរៀបចំនូវការធ្វើកិច្ចសន្យាកសិកម្ម ដែលជាទស្សនទានមួយមានភាពរស់ និងត្រូវបានកំណត់ជាគោលនយោបាយអាទិភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ»។

ជាមួយគ្នានេះដែរ លោក កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ក៏បានសម្តែងនូវមោទនភាពយ៉ាងខ្លាំងដែលអង្ករកម្ពុជា បានឈ្នះជ័យលាភីជា «អង្ករល្អដាច់គេ» របស់ពីភពលោកប្រចាំ ឆ្នាំ២០២២ ក្នុងវេទិកាសន្និសីទអង្ករពិភពលោកដែលធ្វើឡើងក្នុងខេត្តភូកេត ប្រទេសថៃ នាថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០២២ ។

លោកបានថ្លែងថា ៖ «រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ខ្ពស់ចំពោះវិស័យ ស្រូវ-អង្ករ ដោយបានដាក់ចេញនូវវិធានការអន្តរាគមន៍ ជាពិសេសតាមរយៈការផ្តល់ហិរញ្ញប្បទានពិសេសជាទុនវិនិយោគ និងជាទុនបង្វិលតាមអត្រាការប្រាក់ និងលក្ខខណ្ឌសម្បទាន ហើយបានដោះស្រាយបញ្ហាប្រឈមខ្លះ ដូចជា ហេដ្ឋារចនា សម្ព័ន្ធ ឃ្លាំង និងឡសម្ងួត និងបញ្ហាកង្វះទុនបង្វិលសម្រាប់ប្រមូលទិញស្រូវជាជាបន្តបន្ទាប់នាពេលកន្លងមក»។

អភិបាលខេត្តកំពង់ធំ លោក ងួន រតនៈ បានលើកឡើងថា ខេត្តកំពង់ធំ ដែលជាខេត្តមួយសំខាន់ក្នុងការផលិតស្រូវ ហើយបើគិតទាំងស្រូវប្រាំង និងវស្សាមានផ្ទៃដីចំនួនជាង ២៩មុឺនហិកតា ដែលអាចផលិតបានស្រូវចំនួនជាង ៨០មុឺនតោន និងមានអតិរេកស្រូវចំនួនជាង ៥០មុឺនតោនក្នុងមួយឆ្នាំ៕





# លំដាប់លេខរៀងគណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ អាណត្តិទី៧

## ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣

១ – គណបក្ស «សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ» ដែលមានលោក ម៉ម សូណង់ដូ ជាប្រធាន ត្រូវបង្កើតឡើងនៅឆ្នាំ២០១៥ ហើយបានចុះបញ្ជីនៅក្រសួងមហាផ្ទៃនាខែកុម្ភៈ ឆ្នាំ២០១៦។ បើរាប់ចាប់តាំងពីថ្ងៃបង្កើតរហូតមកដល់នាពេលបច្ចុប្បន្ន គឺអាយុកាលចំនួន ៨ឆ្នាំហើយ។

២ – គណបក្ស «ខ្មែររួមតែមួយ» ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៨ ដែលគិតមកទល់ពេលបច្ចុប្បន្ននេះមានអាយុកាល ៥ឆ្នាំហើយ។ លោក គុជ លី គឺជាប្រធានគណបក្សនេះ។

៣ – គណបក្ស «សញ្ជាតិកម្ពុជា» បើរាប់ចាប់តាំងពីថ្ងៃដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃកាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ មកទល់ពេលនេះ គឺមានអាយុកាល ១២ឆ្នាំហើយ។ គណបក្សនេះដែរ មានលោក សេង សុខេង ជាប្រធានបក្ស។

៤ – គណបក្ស «ខ្មែររួបរួមជាតិ» ត្រូវបានបង្កើតនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៦ គិតមកទល់ពេលនេះ គណបក្សនយោបាយកណ្ដាលនិយមមួយនេះ ក្រោមការដឹកនាំរបស់អ្នកនយោបាយចាស់វស្សា លោក ញឹក ប៊ុនឆៃ មានអាយុកាល៧ឆ្នាំហើយ។

៥ – គណបក្ស «កម្លាំងប្រជាធិបតេយ្យ» ត្រូវបានក្រសួងមហាផ្ទៃទទួលស្គាល់ជាផ្លូវការនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០។ គិតមកទល់ពេលនេះ គឺមានអាយុកាល ៣ឆ្នាំ ហើយគណបក្សនេះ មានលោក អ៊ុន វិសិទ្ធគុន ជាប្រធាន។

៦ – គណបក្ស «កសិករ» គឺជាបក្សដែលមានលោក មាស បូពៅ ជាប្រធាននេះ។ គណបក្សនេះមានអាយុកាល ៣៥ឆ្នាំហើយ បើរាប់តាំងពីថ្ងៃបង្កើតឡើងនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៨៨ នៅជំរុំសាយធូ លើភ្នំដងរែក។

៧ – គណបក្ស «ស្ត្រី ដើម្បីស្ត្រី» ដែលមានលោកស្រី ស៊ឹង សុធី ជាប្រធានបក្ស គិតមកទល់ពេលនេះមានអាយុកាល ២៤ឆ្នាំហើយរាប់ចាប់តាំងពីការបង្កើតឡើងនៅឆ្នាំ ១៩៩៩ ។

៨ – គណបក្ស «ខ្មែរឈប់ក្រ» មានអាយុកាល ១៦ឆ្នាំហើយបើរាប់ចាប់តាំងពីត្រូវបានក្រសួងមហាផ្ទៃទទួលស្គាល់ជាផ្លូវការនៅខែកញ្ញា ឆ្នាំ២០០៧ ។ គណបក្សដែលទាក់ទាញប្រជាពលរដ្ឋឲ្យមានការចាប់អារម្មណ៍តាមរយៈឈ្មោះថា គណបក្សខ្មែរឈប់ក្រនេះ គឺមានលោក ក្រវ៉ាញ ដារ៉េន ជាប្រធាន។

៩ – គណបក្ស «ហ្វុនស៊ិនប៉ិច» គឺជាបក្សដែលមានថ្នាក់ដឹកនាំជាប់ខ្សែរាជវង្ស មានអាយុកាល៤២ឆ្នាំ ហើយបើគិតចាប់តាំងពីការបង្កើតឡើងនៅថ្ងៃទី២១ខែមីនាឆ្នាំ១៩៨១ ។ សព្វថ្ងៃនេះ ប្រធានគណបក្សគឺជាព្រះអង្គម្ចាស់នរោត្ដម ចក្រាវុធ។

១០ – គណបក្ស «ធម្មាធិបតេយ្យ» មានអាយុកាល២៥ឆ្នាំហើយគិតដល់សព្វថ្ងៃនេះ។ គណបក្សនេះ មានប្រធានជាស្ត្រី គឺលោកស្រី ពោធិគី សាវត្ថី ហើយត្រូវបានបង្កើតឡើង និងចុះបញ្ជីនៅក្រសួងមហាផ្ទៃក្នុងឆ្នាំ ១៩៩៨ ។

១១ – គណបក្ស «ប្រជាធិបតេយ្យមូលដ្ឋាន» ត្រូវបានបង្កើតនៅថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១៥ គិតមកដល់ថ្ងៃនេះ គណបក្សដែលមានលោក យ៉េង វិរៈ ជាប្រធាន មានអាយុកាលជិត៨ឆ្នាំហើយ។

១២ – គណបក្ស «បំណងពលរដ្ឋ» ត្រូវបានក្រសួងមហាផ្ទៃទទួលស្គាល់នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលគិតចាប់ពីពេលនោះមក គឺគណបក្សនេះមានអាយុកាល៤ឆ្នាំ ហើយលោក អ៊ិត សារម្យ ជាប្រធានគណបក្ស។

១៣ – គណបក្ស «ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច» មានអាយុកាល ១១ឆ្នាំហើយ ជាគណបក្សដែលមានលោក ហួន ច័ន្ទថុន ជាប្រធាន។ គណបក្សនេះ ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ។

១៤ – គណបក្ស «ឯកភាពជាតិខ្មែរ» ត្រូវបានក្រសួងមហាផ្ទៃទទួលស្គាល់ជាផ្លូវការនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ ។ គណបក្សដែលមានលោក អ៊ុន ជីម ជាប្រធាននេះ មានអាយុកាល ៣ឆ្នាំហើយ។

១៥ – គណបក្ស «ខ្មែរអភិរក្ស» របស់លោក រៀល ខេមរិន្ទ្រ ត្រូវបានក្រសួងមហាផ្ទៃទទួលស្គាល់ជាផ្លូវការណ៍នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ ។ បើគិតមកទល់ពេលនេះ គណបក្សនេះ មានអាយុកាលជិត ៤ឆ្នាំហើយ។

១៦ – គណបក្ស «យុវជនកម្ពុជា» គឺជាគណបក្សរបស់លោកបណ្ឌិត ពេជ្រ ស្រស់ ដែលបានបង្កើតឡើងនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥។ បើគិតមកទល់ពេលនេះ មានរយៈពេលជាង ៧ឆ្នាំហើយ។

១៧ – គណបក្ស «ជនជាតិដើមប្រជាធិបតេយ្យកម្ពុជា» ដែលគិតមកទល់បច្ចុប្បន្ននេះ មានអាយុកាល៧ឆ្នាំហើយ ដោយប្រធានបក្សលោក ប្លាង សីន បានបង្កើតគណបក្សនេះនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ។

១៨ – គណបក្ស «ប្រជាជនកម្ពុជា» គឺជាបក្សដែលមានវ័យចំណាស់ជាងគេ ពោល គឺមានអាយុកាល៧២ឆ្នាំហើយ បើគិតចាប់ពីថ្ងៃបង្កើតបក្សនេះដំបូងនៅថ្ងៃទី២៨ខែមិថុនា ឆ្នាំ១៩៥១ និងបានចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ក្នុងឆ្នាំ ១៩៩៨។

# ឌីជេ ណាណា ជំរុញឱ្យក្មេងស្រីទាំងអស់មិនត្រូវបោះបង់ និងត្រូវក្លាហានពុះពារបន្តក្តីស្រមៃរបស់ខ្លួន

*អត្ថបទ៖ ម៉ុត ពេជ្រហ្សាលីន*

មនុស្សគ្រប់រូបសុទ្ធតែមានក្តីសុបិន ពិសេសក្មេងស្រីតែងមានបំណងប្រាថ្នា និងមានគោលដៅច្បាស់លាស់រៀងៗខ្លួន ប៉ុន្តែក្តីស្រម៉ៃ និងបំណងប្រាថ្នាទាំងនោះអាចសម្រេចបាន ឬមិនបាន គឺពឹងផ្អែកទៅលើសកម្មភាពរាល់ថ្ងៃដែលអ្នកកំពុងតែធ្វើនេះឯង ថាតើអ្នកខំប្រឹងធ្វើវាឲ្យអស់ពីសមត្ថភាពហើយឬនៅ ឬគ្រាន់តែធ្វើវាច្បោលៗទេ?

ពាក់ព័ន្ធនឹងក្តីស្រម៉ៃ និងគន្លឹះជំរុញចិត្តដល់យុវវ័យ ពិសេសក្មេងស្រី ដើម្បីមានភាពក្លាហានឆ្ពោះទៅឈាន ចាប់ក្តីស្រម៉ៃរបស់របស់ខ្លួន អ្នកយកព័ត៌មានអ្នកនាំសារបានធ្វើបទសម្ភាសជាមួយនឹងអ្នកនាង នាង សុវឌ្ឍនា ឬយុវវ័យភាគច្រើនស្គាល់ថាជា DJ NANA ដែលអ្នកនាងក៏ជាឯកអគ្គរាជទូតកិត្តិយសរបស់អង្គការផ្លែនអន្តរជាតិកម្ពុជាផងដែរ។

តើអ្នកនាងសង្កេតឃើញថា ស្ថានភាពក្មេងស្រីនៅកម្ពុជា ភាគច្រើនទទួលរងឥទ្ធិពល និងបញ្ហាអ្វីខ្លះ?

សម្រាប់ខ្ញុំឆ្លងតាមបទពិសោធន៍ប៉ុន្មានឆ្នាំចុងក្រោយ ដែលបានធ្វើការជាឯកអគ្គរាជទូតកិត្តិយសរបស់អង្គការផ្លែនអន្តរជាតិកម្ពុជា ដែលភាគច្រើនខ្ញុំធ្វើការពាក់ព័ន្ធនឹងការជំរុញចិត្តក្មេងស្រី ខ្ញុំយល់ថាក្មេងប្រុសនិងក្មេងស្រី ជួបប្រទះឧបសគ្គក្នុងការរស់នៅក្នុងសង្គមដូចគ្នា ប៉ុន្តែអ្វីដែលខុសគ្នានៅត្រង់ថា ក្មេងស្រីត្រូវបានសង្គមបង្រៀននូវរឿងអ្វីដែលមិនគួរធ្វើច្រើនជាងក្មេងប្រុស។ កត្តានេះបានជំរុញឱ្យក្មេងស្រីរស់នៅក្នុងភាពភ័យខ្លាចនៃការរើសអើង ការមាក់ងាយ និងទទួលរងអំពើហិង្សានានាជាដើម។

ក្រៅពីកត្តាសង្គម ដែលបានបង្រៀននូវរឿងអ្វីដែលមិនគួរធ្វើច្រើនជាងក្មេងប្រុសហើយនោះ កត្តាក្មេងស្រីខ្លួនឯងផ្ទាល់ ដោយសារតែពួកគេមិនហ៊ានជម្នះឧបសគ្គដើម្បីសម្រេចក្តីស្រមៃរបស់ខ្លួន នឹងកាន់តែធ្វើឱ្យពួកគេបាក់ទឹកចិត្តជាខ្លាំងផងដែរ។

តើបញ្ហា ឬកត្តាអ្វីខ្លះ ដែលបានរារាំងក្មេងស្រីឱ្យងាយបោះបង់ក្តីស្រម៉ៃរបស់ខ្លួន?

សម្រាប់ខ្ញុំ មើលឃើញកត្តាចម្បងៗចំនួន៤ ដែលបានរារាំងក្មេងស្រីដើម្បឆ្ពោះទៅរកក្តីស្រម៉ៃរបស់ខ្លួនក្នុងនោះរួមមាន៖

ទី១ កត្តាក្មេងស្រីខ្លួនឯង៖ មិនទាន់ស្គាល់ពីខ្លួនឯងច្បាស់ ថាតើខ្លួនឯងចូលចិត្តអី? ចង់ធ្វើអី? និងការជះឥទ្ធិពលទៅវិញទៅមករវាងកង្វះចំណាប់អារម្មណ៍ និងបញ្ហាជួបប្រទះក្នុងការសិក្សា។ កង្វះចំណាប់អារម្មណ៍ និងកង្វះឆន្ទៈ ធ្វើឱ្យបញ្ហាពាក់ព័ន្ធកើនឡើងជាលំដាប់ពីមួយថ្ងៃទៅមួយថ្ងៃ ហើយបញ្ហានេះបានជះឥទ្ធិពលអវិជ្ជមានទៅលើចំណាប់អារម្មណ៍ និងឆន្ទៈរបស់ក្មេងស្រី។

ទី២ កត្តាគ្រួសារ៖ ជីវភាពគ្រួសារក្រីក្រក៏ជាបញ្ហាប្រឈមមួយធ្ងន់ធ្ងរដែរ ដែលបណ្តាលឱ្យសិស្សស្រី ពិសេសក្មេងស្រីងាយបោះបង់ការសិក្សា។ ក្មេងស្រីកើតមក និងរស់នៅជាមួយគ្រួសារតាំងពីតូច ហើយគ្រួសារបានក្លាយជាការសម្រេចចិត្តលើអនាគតរបស់ពួកគេ រួមទាំងការសិក្សាផងដែរ។ គ្រួសារក្រីក្រមួយចំនួនតែងតែផ្លាស់ប្តូរទីលំនៅ និងនាំកូនរបស់ទៅជាមួយ ដើម្បីជួយធ្វើការតាមដែលអាចធ្វើទៅបាន ដូចជាការធ្វើស្រែចម្ការ ឬការរកលុយដើម្បីចិញ្ចឹមជីវិត។ យ៉ាងណាមិញ ខ្ញុំសំណូមពរឱ្យក្រុមគ្រួសារលើកទឹកចិត្តក្មេងស្រីដើម្បីទាមទារឱ្យមានការប្រឆាំងនឹងការរើសអើង ដែលរារាំងឱកាសរបស់ស្ត្រី និងក្មេងស្រីផងដែរ។

ទី៣ កត្តាសាលារៀន៖ សាលារៀនជាកត្តា



ដែលគួរឱ្យកត់សម្គាល់ និងពិចារណាលើបញ្ហាដែលបណ្តាលឱ្យសិស្សស្រីងាយបោះបង់ការសិក្សាផងដែរ។ គំរូទ្រឹស្តីពន្យល់ពីការបោះបង់ការសិក្សាបានបង្ហាញថា ក្មេងស្រី និងបរិស្ថាននៃថ្នាក់រៀនរបស់ពួកគេ ព្រមទាំងទំនាក់ទំនងរបស់ពួកគេនៅសាលារៀនជាកត្តាសំខាន់បំផុតក្នុងការព្យាករណ៍ពីភាពជោគជ័យ និងការបោះបង់ការសិក្សា។ តាមការស្រាវជ្រាវរបស់ Khan, Azhar and Shah នៅឆ្នាំ២០១១ បានបង្ហាញថា បញ្ហានៅក្នុងសាលារៀនដែលជះឥទ្ធិពលអវិជ្ជមានដល់សិស្សដូចជា សមត្ថភាពគ្រូ កម្រិតនៃកម្មវិធីសិក្សាលំបាកខ្លាំង និងវិធីសាស្ត្របង្រៀនមិនមានភាពទាក់ទាញជាដើម។

រីឯទី៤ គឺកត្តាសហគមន៍ និងអាជ្ញាធរ៖ សហគមន៍ក៏ជាកត្តាមួយដែលទាក់ទងដល់ការសម្រេចចិត្តបោះបង់ការសិក្សារបស់សិស្សជាពិសេសសិស្សស្រីផងដែរ។ សិស្សអាចបន្តការសិក្សានៅសាលារៀនបានយូរអង្វែងអាស្រ័យលើការលើកទឹកចិត្តពីខ្លួនគេផ្ទាល់ និងមនុស្សនៅជុំវិញ។ តាមការស្រាវជ្រាវរបស់ Natriello ក្នុងឆ្នាំ២០១២ បានបញ្ជាក់ថា ទីណាដែលមានការគាំទ្រទាបពីសំណាក់សហគមន៍ទីនោះមានការបោះបង់ការសិក្សាច្រើន។ ហេតុនេះ ទើបសង្កេតឃើញថា បច្ចុប្បន្នអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធបានយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងទប់ស្កាត់ការបោះបង់ការសិក្សា ពិសេសសិស្សស្រី ដោយបានដាក់ចេញជាវិធានការនានានៅតាមសហគមន៍ជាពិសេសនៅតាមសាលារៀនដែលប្រឈមនឹងការបោះបង់ការសិក្សាខ្ពស់ផងដែរ។

ចំនុចទាំង៤នេះ ភាគច្រើនកើតឡើងចំពោះក្មេងស្រីជំនាញមុន យ៉ាងណាមិញ មកដល់បច្ចុប្បន្ននេះ តើអ្នកនាងមើលឃើញថា ក្មេងស្រីសម័យនេះខុសពីសម័យមុនដូចម្តេចខ្លះ?

យុវនារីក្មេងស្រីៗសម័យនេះខុសពីសម័យមុន។





ខ្ញុំសម័យឥឡូវអាយុជាង៣០ ខុសពីម្តាយខ្ញុំអាយុជាង៣០ កាលគាត់អាយុជាង៣០ គាត់អត់មានបរិយាកាសបែបហ្នឹងទេ។ ខ្ញុំខុសគ្នា ក្នុងវ័យជាង៣០ឆ្នាំរបស់ខ្ញុំមានអីនធឺណិត មានទូរសព្ទអីចឹងទៅ។ ក្មេងជាងហ្នឹងទៀត អាយុ ១៥-១៦ឆ្នាំ កាលម្តាយគាត់អាយុ១៥-១៦ឆ្នាំ ស្ថានភាពអត់ដូចគ្នាទេ។ អីចឹង យើងមិនគួរគិតថា ដោយសារតែម៉ាក់យើង ដោយសារតែអ៊ុំស្រីយើង ដោយសារតែមេឃុំជាស្ត្រីដែលយើងស្គាល់មានឧបសគ្គច្រើន វាក្លាយជាកត្តាដែលធ្វើឱ្យយើងបាក់ទឹកចិត្ត គឺអត់ទេ ព្រោះយើងកើតនៅក្នុងបរិយាកាសមួយដែលប្រសើរជាងគាត់ស្រាប់ទៅហើយ។

ជាចុងក្រោយ តើអ្នកនាងមានគន្លឹះ និងសារអ្វីខ្លះ ដើម្បីចែករំលែកទៅកាន់ក្មេងស្រី ដើម្បីជំរុញពួកគាត់កុំឆាប់បោះបង់ និងត្រូវក្លាហានពុះពារបន្តក្តីស្រមៃរបស់ខ្លួន?

ក្នុងនាមខ្ញុំ ជាឯកអគ្គរាជទូតកិត្តិយសរបស់អង្គការផ្លែនអន្តរជាតិកម្ពុជា ហើយធ្វើផ្ទាល់ជាមួយក្មេងស្រីនាពេលកន្លងមក ខ្ញុំបានចែករំលែកគន្លឹះសំខាន់ៗចំនួន៣ចំនុច ទៅក្មេងស្រី ដើម្បីជំរុញឱ្យក្មេងស្រីទាំងអស់ ក្លាហានពុះពារបន្តក្តីស្រមៃខ្លួន។ ចំណុចទី១ ក្មេងស្រីត្រូវយល់ថា ក្តីស្រមៃជាសេរីភាពគ្មានព្រំដែន។ យើងចង់គិតអីក៏បាន ដោយសារនៅក្នុងការគិតរបស់យើង វាអត់មានដែនកំណត់ទេ សេចក្តីស្រមៃ មិនត្រូវគួរបានអនុម័តទេ មិនមែនបានន័យថា យើងមានសិទ្ធិស្រមៃនេះ តែយើងអត់សិទ្ធិស្រមៃនោះ នោះទេ។ ខ្ញុំចង់ឱ្យក្មេងៗសួរតែខ្លួនឯងបានហើយថា ខ្លួនឯងមានសេចក្តីស្រមៃចង់បានអញ្ចេះ ឬចង់ធ្វើនេះ ឬនោះ ហើយសួរយោបល់អ្នកដទៃថា ត្រូវធ្វើម៉េចឱ្យបាន ប៉ុន្តែមិនមែនសួរយោបល់អ្នកដទៃដើម្បីថាខ្ញុំធ្វើអីចឹងបានឬអត់នោះទេ។

ចំណែកចំណុចទី២ គឺនៅពេលយើងមានសេចក្តីស្រមៃ កុំស្ទាក់ស្ទើរនៅក្នុងការរុករកបន្ថែមទៀតលើសពីហ្នឹង។ មិនមែនបានន័យថាក្តីស្រមៃរបស់យើងមានតែមួយទេ មនុស្សអាចមានក្តីស្រមៃច្រើនជាងមួយ។ ដូច្នេះហើយកុំកំណត់ខ្លួនឯង មើលក្តីស្រមៃចប់មិនមែនបានន័យថា ខុសពីហ្នឹងយើងមិនអាចធ្វើបាននោះទេ ស្អីក៏យើងអាចធ្វើបានដែរ។

រីឯចំណុចទី៣ ដែលជាចំណុចចុងក្រោយ ខ្ញុំយល់ថា ក្មេងប្រុសក៏ដោយ ក្មេងស្រីក៏ដោយ ត្រូវទុកចិត្តលើខ្លួនឯង។ ត្រូវទុកចិត្តថា វាសនាមិនបានចារឱ្យយើងមកនៅអីចឹងទេ វាសនាគ្រាន់បញ្ជាក់ថាយើងកើតនៅឯណា កើតនៅភូមិអី ប៉ាម៉ាក់ឈ្មោះអី មានបងប្អូនប៉ុន្មាននាក់ ប៉ុន្តែវាសនាមិនមែនជាអ្នកកំណត់ថាយើងត្រូវដើរទៅដល់ណាឡើយ។ ហេតុនេះ ខ្ញុំសង្ឃឹមថា ចំនុចទាំងនេះ នឹងក្លាយជាចំណែកខ្លះ ជួយជំរុញឱ្យក្មេងស្រីទាំងអស់មិនបោះបង់ និងត្រូវក្លាហានពុះពារបន្តក្តីស្រមៃរបស់ខ្លួនបាន៕



# ក្រុងថ្មីមួយកំពុងតែលេចរូបរាងឡើង នៅកណ្ដាលព្រៃនៃ ឧទ្យានជាតិបុទុមសាគរ

*អត្ថបទ៖ នរិន្ទបុត្រ*

កំពង់ផែខ្នាតតូច កំពង់ផែខ្នាតមធ្យម សំណង់ព្រោងព្រាត រហូតដល់ព្រលានយន្តហោះ កំពុងតែលេចរូបរាងឡើងនៅកណ្ដាលព្រៃនៃឧទ្យានជាតិបុទុមសាគរ ដែលមានទីតាំងសណ្ដូកតាម បណ្ដោយឆ្នេរនៃឈូងសមុទ្រថៃ។

ទីនោះ មិនចេះតែអនុញ្ញាតឲ្យប្រជាពលរដ្ឋចេញចូលផ្ដេសផ្ដាសឡើយ ពីព្រោះមួយគម្រោងទៅ មួយគម្រោងសុទ្ធតែមានក្រុមសន្តិសុខដាក់ប៉ុស្តិ៍ត្រួតពិនិត្យ និងសួរនាំ ហើយក៏មិនបានសាងសង់ដោយសម្ងាត់ដែរ គ្រាន់តែតម្រូវឲ្យចុះសុំការអនុញ្ញាតពីសន្តិសុខ និងមានការថតរូប រថយន្ត នៅក្នុងហេតុផលដើម្បីសន្តិសុខតែប៉ុណ្ណោះ។

នៅទីនេះគម្រោងដែលកំពុងតែលេចរូបរាង និងប្រាកដបំផុត គឺមានសណ្ឋាគារជាច្រើនកន្លែង វីឡា បុរីដ៏ប្រណីតនៅកណ្ដាលទ្រូងព្រៃ កាស៊ីណូ ហាងទំនើបខ្នាតមធ្យម រីសត កំពង់ផែទេសចរណ៍ខ្នាតតូច និង មធ្យម និងព្រលានយន្តហោះ ហើយអ្វីដែលកំពុងតែសាងសង់ គឺមានច្រើន។

លោក កែប ភា ប្រជាពលរដ្ឋដែលបានមកលេងបងប្អូននៅក្រុងកូនកុក បានឲ្យដឹងថា ពីមុនគេមិនឲ្យចេញចូលទេ ប៉ុន្តែពេលនេះលោកអាចចេញចូលបាន ដោយគ្រាន់តែប្រាប់សន្តិសុខ ហើយគេក៏អាចនឹងឱ្យគ្រប់គ្នាជាអ្នកទេសចរមកលេងកំសាន្តនៅទីនេះផងដែរ។

និយាយបណ្ដើរហូបបាយជាមួយនឹងគ្រួសារបណ្ដើរ នៅក្នុងរីសតមួយកន្លែងនៅក្នុងគម្រោងនេះ លោក កែប ភា បានឲ្យដឹងថា ៖ «អូហ៍! ធំណាស់ បើកឡានមិនស្រួលវង្វេង តែខ្ញុំបានទៅត្រឹមតែរីសត និងឆ្នេរនេះទេ តែប្អូនគាត់ប្រាប់ថាទីនេះមានទាំងសណ្ឋាគារ កាស៊ីណូ ហើយឮប្អូនប្រាប់ថា មានទាំងព្រលានយន្តហោះថែមទៀត»។

បុគ្គលិកសណ្ឋាគារមួយរូបបានឲ្យដឹងដោយសុំមិនបញ្ចេញឈ្មោះថា បុគ្គលិកខ្មែរយើងនៅទីនេះមានរាប់រយនាក់ ដោយខ្លះជាកម្មករសំណង់ ខ្លះនៅកសិដ្ឋានចិញ្ចឹមមាន់ ខ្លះជាបុគ្គលិកនៅកាស៊ីណូ សណ្ឋាគារ ភោជនីយដ្ឋាន។

លោកបានបញ្ជាក់ថា៖ «ខ្ញុំមិនសូវដឹងច្រើនទេ ប៉ុន្តែគ្រាន់តែថា គម្រោងធំណាស់ ហើយនៅពេលនេះ ដូចជាមានកន្លែងសាងសង់អគារ៥០ ជាន់នៅឆ្នេរមួយកន្លែង ហើយនៅមានសួនទឹក រីឯព្រលានយន្តហោះ សាងសង់ហើយ តែមិនទាន់ដំណើរការ ប៉ុណ្ណោះ» ។

លោកបានបន្តថា នៅពេលនេះអតិថិជននៃគម្រោងសណ្ឋាគារ វីឡា កាស៊ីណូ រីសត កន្លែងវ៉ៃកូនហ្គោល គឺភាគច្រើនមានតែចិនទេ ហើយខ្មែរគឺមានតិចតួច បើច្រើនគឺតែពេលបុណ្យទានតែប៉ុណ្ណោះ ដូចជាពេលចូលឆ្នាំប៉ុណ្ណោះ ។

នារីបុគ្គលិកមួយរូប ដែលប្រាប់ឈ្មោះត្រឹមថា សម្ផស្ស បានឲ្យដឹងថា អ្នកនៅធ្វើការនៅទីនេះ គឺមកពីកន្លែងផ្សេងៗ តាំងពីតាកែវ កំពត កំពង់ចាម និងខេត្តកោះកុងជាដើម។

កញ្ញា សម្ផស្ស បានឲ្យដឹងថា ៖ «ដូចខ្ញុំ និងបងប្រុសម្នាក់ គឺមកពីកំពត ហើយក៏មានមិត្តភ័ក្រខ្លះមកតាំងពី ក្រចេះ»។

កញ្ញាបានបន្តទៀតថាធ្វើការនៅទីនេះមិនសូវបានដើរទៅណាទេពីព្រោះវានៅតែក្នុងព្រៃហើយ មានបាយ មាន កន្លែងស្នាក់នៅ ហូបចុកស្រួល ហើយបើចង់មានពិធីអីគឺនាងអាចទៅឆ្នេរឬរីសត ដែលមានទាំងកន្លែងថ្លៃ និងថោក ហើយចង់បាននំខេកអីមានទាំងអស់។

តាមការស្រាវជ្រាវ គេដឹងថា ទីក្រុងកណ្ដាលព្រៃនេះ គឺកំពុងតែអភិវឌ្ឍន៍ក្រោមគម្រោងរបស់ក្រុមហ៊ុនចិនមួយដែលមានឈ្មោះថា Tianjin Union Development Group ដែលទទួលបានសិទ្ធិសម្បទានវិនិយោគនៅទីនោះ ៩៩ ឆ្នាំ តាំងពីឆ្នាំ ២០០៨ មក នៅលើផ្ទៃដីសរុបដល់ទៅ ៤៥.០០០ ហិកតា មានតម្លៃប្រមាណជា ៣,៨ពាន់លានដុល្លារ។

គម្រោងនេះគឺជាគម្រោងវិនិយោគទុនឯកជន ប៉ុន្តែក្រុមអ្នកវិភាគខ្លះបាន អះអាងថា វាគឺជាគម្រោងមួយ ដែលមានលក្ខណៈយុទ្ធសាស្ត្រខាងយោធារបស់ចិន៕

# ស្ថានភាពសត្វរំពេទន្លេនៅក្នុងតំបន់មេគង្គស្ថិតក្នុងចំនួនមួយថេរក្នុងរយៈពេល២ឆ្នាំចុងក្រោយ

*អត្ថបទ៖ ផល សុផានិត*

ស្ថានភាពសត្វរំពេទន្លេនៅក្នុងតំបន់មេគង្គស្ថិតក្នុងចំនួនមួយថេរក្នុងរយៈពេល២ឆ្នាំ ចុងក្រោយនេះ ដោយអ្នកវិទ្យាសាស្ត្របានកត់ត្រាទុកវត្តមានរបស់សត្វនេះសរុបចំនួន ៧១ ក្បាល ព្រមទាំងកូនសត្វរំពេទន្លេដែលទើបនឹងញាស់មានសុខភាពល្អចំនួន ៣ ក្បាល ទៀត ក្នុងឆ្នាំ២០២៣ នេះ។

នេះបើយោងតាមសេចក្ដីរាយថ្មីមួយកាលពីដើមសប្ដាហ៍នេះស្ដីពីការគ្រប់គ្រងសំបុក និងរាប់ចំនួនសត្វរំពេទន្លេនៅក្នុងតំបន់ទីជម្រកនៃព្រៃទេសភាពទន្លេមេគង្គ ដែលដឹកនាំអនុវត្តដោយក្រុមអ្នកស្រាវជ្រាវនៃអង្គការមូលនិធិសកលសម្រាប់អភិរក្សធម្មជាតិ (WWF) នៅចន្លោះខែកុម្ភៈដល់ខែមេសា ឆ្នាំ២០២៣ ដោយមានការចូលរួមពីសមាជិកសហគមន៍មូលដ្ឋានក្នុងសកម្មភាពការងារផងដែរ។

បើតាមអង្គការ WWF ចំនួនសត្វរំពេទន្លេក្នុងឆ្នាំ២០២៣នេះ ជាចំនួនកើនឡើង ដល់ទៅប្រមាណជិត ១៣០ ភាគរយបើប្រៀបធៀបជាមួយនឹងលទ្ធផលតាមដានចំនួនសត្វនេះទទួលបានកាលពី ៧ ឆ្នាំមុន ពោលគឺពីចំនួនត្រឹមតែ ៣១ ក្បាល ក្នុងឆ្នាំ ២០១៦ កើនដល់ ចំនួន ៧១ ក្បាល ក្នុងឆ្នាំ ២០២៣នេះ។

អង្គការ WWF បានបញ្ជាក់ថា ៖ «បច្ចុប្បន្នសត្វរំពេទន្លេព្រមទាំងកូនទាំងនេះកំពុងរស់នៅយ៉ាងសុខសាន្តក្នុងសំបុកសរុបចំនួន ៣១ សំបុក ដែលស្ថិតក្រោមការការពារដោយសហគមន៍មូលដ្ឋានដែលរស់នៅជាប់នឹងតំបន់ទីជម្រកតាមដងទន្លេមេគង្គក្នុងខេត្តក្រចេះ និងស្ទឹងត្រែង»។

អ្នកនាំពាក្យក្រសួងបរិស្ថាន លោក នេត្រ ភក្ត្រា បានបង្ហាញពីក្ដីរំភើប ចំពោះការកើនឡើងនៃចំនួនសត្វរំពេទន្លេ ដែលជាប្រភេទសត្វកម្ររបស់ប្រទេសកម្ពុជា។

លោកបានប្រាប់ថា ៖ «ការកើនឡើងនេះដោយសារតែការចូលរួមការពារ និងអភិរក្សពីប្រជាពលរដ្ឋ ខការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះប្រភេទសត្វកម្រមួយនេះ ទន្ទឹមនឹងការខិតខំការពារជំរករបស់សត្វរំពេផងនោះ ធ្វើឱ្យប្រភេទសត្វកម្រមួយនេះអាចមានលទ្ធភាពបន្តពូជជាបន្តបន្ទាប់»។

សត្វរំពេ បានចាត់ថ្នាក់ជាប្រភេទសត្វងាយរងគ្រោះក្នុងបញ្ជីក្រហម IUCN សត្វរំពេទន្លេជាបក្សីដ៏កម្រមួយប្រភេទនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ នៅក្នុងប្រទេសកម្ពុជា ចំនួនសត្វនេះបានថយចុះយ៉ាងខ្លាំង រហូតដល់ទៅជាង ៨០ភាគរយ ក្នុងរយៈពេល ២០ឆ្នាំ ចុងក្រោយ ដោយមូលហេតុចំបងៗនៃការធ្លាក់ចុះ ភាគច្រើនបណ្ដាលមកពីសកម្មភាពរបស់មនុស្ស។

# សត្វត្មាតព្រៃធម្មជាតិកម្ពុជាឆ្នាំ២០២២ កើនឡើងជាងឆ្នាំ២០២១

*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រសួងបរិស្ថាន បានប្រកាសឱ្យដឹងពីលទ្ធផលជំរឿនសត្វត្មាត ២០២២ កន្លងទៅកាន់តែមានសញ្ញាណវិជ្ជមាន ដោយចំនួនសត្វត្មាតក្នុងព្រៃធម្មជាតិកម្ពុជាមានការកើនឡើងធៀបនឹងឆ្នាំ២០២១ មានការកើនឡើងចំនួន១៣ក្បាល។

យោងតាមលទ្ធផលជំរឿនបានបង្ហាញថា ស្ថានភាពសត្វត្មាតកម្ពុជាក្នុងឆ្នាំ ២០២២ កន្លងទៅកាន់តែមានសញ្ញាណវិជ្ជមាន ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអភិរក្សសត្វត្មាតកម្ពុជា ប៉ុន្តែចាំបាច់ទាមទារនូវការបង្កើនការយកចិត្តទុកដាក់ពីគ្រប់ភាគីក្នុងការការពារនិងអភិរក្សសត្វកម្រនេះបន្ថែមទៀត។

ក្រសួងបរិស្ថានបញ្ជាក់ថា ៖ «នៅឆ្នាំ ២០២២ ជំរឿនបានបង្ហាញលទ្ធផលថា កម្ពុជាមានសត្វត្មាតទាំង៣ប្រភេទសរុបចំនួន ១៣៤ ក្បាល ក្នុងនោះរួមមានត្មាតផេះ ៧១ ក្បាល ត្មាតត្នោត ៤៤ ក្បាលនិងត្មាតភ្លើង ចំនួន ១៩ក្បាល។ ចំនួនសត្វត្មាត មានការកើនឡើងចំនួន ១៣ ក្បាលបើប្រៀបធៀបនឹងឆ្នាំ ២០២១ ដែលមានចំនួន ១២១ ក្បាល»។

លទ្ធផល ជំរឿនសត្វត្មាតថ្នាក់ជាតិឆ្នាំ ២០២១ បានបង្ហាញថា សត្វត្មាត មានចំនួនសរុបចំនួន ១២១ ក្បាលក្នុងនោះ មានត្មាតភ្លើង ២០ ក្បាល ត្មាតផេះ ៦៦ ក្បាល និង ត្មាតត្នោត ៣៥ ក្បាល។

អ្នកនាំពាក្យក្រសួងបរិស្ថាន លោក នេត្រ ភក្ត្រា បានឱ្យដឹងថា ការកើនឡើងនេះ ជាដំណឹងដ៏ល្អ សម្រាប់ក្រុមអ្នកអភិរក្ស និងសម្រាប់ជីវៈចម្រុះនៅប្រទេសកម្ពុជា និងនៅលើពិភពលោក។

សមាជិកស្នូលនៃក្រុមអភិរក្សសត្វត្មាតកម្ពុជា (CVWG) រួមមានក្រសួងបរិស្ថាន (MoE) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF) មជ្ឈមណ្ឌលអង្គរសម្រាប់អភិរក្សជីវៈចម្រុះ (ACCB) អង្គការជីវិតធម្មជាតិនៅកម្ពុជា (BirdLife in Cambodia) អង្គការសមាគមអភិរក្សសត្វព្រៃ(WCS) អង្គការមូលនិធិសកលសម្រាប់អភិរក្សធនធានធម្មជាតិ (WWF)។ ក្រុមហ៊ុនRising Phoenix និងសមាជិកសាមញ្ញរួមមានសមាគមមគ្គុទ្ទេសក៍បក្សីកម្ពុជា(CBGA) សំ វាសនា ខន់សីវេសិនធួរ (SVC) និងមជ្ឈមណ្ឌលអភិរក្សជីវៈចម្រុះ (CBC) នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងដៃគូពាក់ព័ន្ធបានធ្វើការងារលើការអភិរក្សសត្វត្មាតនៅកម្ពុជា៕



# សង្ខេបព្រឹត្តិការណ៍សង្គមអន្តរជាតិ

## រុស្ស៊ីកំពុង រៀបចំប្រមូលអាវុធយុទ្ធភ័ណ្ឌពីក្រុមទាហានស៊ីឈ្នួល




*អត្ថបទ៖ នរិន្ទបុត្រ*

ទីក្រុងមូស្គូ បានអះអាងថា នៅពេលនេះខ្លួនកំពុងតែរៀបចំដំណើរការប្រមូលអាវុធពីក្រុមទាហានស៊ីឈ្នួល ។ ផែនការណ៍នេះបានត្រូវរៀបចំឡើងក្រោយពេលដែលលោកវ្លាឌីមៀ ពូទិន បានប្រកាសថា លោកនឹងមិនបោះបង់ក្រុមនេះទេ ហើយបានអរគុណដែលក្រុមទាហានស៊ីឈ្នួលមិនបង្កឲ្យមានសង្គ្រាមស៊ីវិលនៅក្នុងរុស្ស៊ី។

ថ្លែងប្រាប់សមាជិកកម្លាំងសន្តិសុខ កងឆ្មាំសន្តិសុខ និងមេបញ្ជាការយោធា ប្រមាណជា ២.៥០០ នាក់ លោកពូទីន បាននិយាយថា នេះគឺជាដំណោះស្រាយ និងជាសេចក្តីក្លាហានរបស់យើង ហើយវានឹងឆ្លុះបញ្ចាំងអំពីស្មារតីនៃការរួបរួមនៃសង្គមរុស្ស៊ីទាំងមូល។

លោកបានលើកឡើងថា សង្គមរុស្ស៊ីគឺមានភាពរឹងមាំ ហើយតែងតែយកឈ្នះនូវរាល់ឧបសគ្គ និងបញ្ហាជាច្រើនដែលបានប្រឈម។

លោកបានបន្តទៀតថា យើងអាចមើលឃើញច្បាស់ហើយអំពីឆន្ទៈរបស់កងកម្លាំងយោធា សង្គម និង ប្រជាជន។ យោធា សង្គម និងប្រជាជនរុស្ស៊ីគឺតែមួយហើយស្មារតីនេះនឹងនាំឲ្យរុស្ស៊ីអាចឈានទៅរកជ័យជំនះប្រឆាំងនឹងស្ថានការណ៍លំបាកនានា ដែលប្រទេសកំពុងតែ កើតមាន៕



បន្ទាប់ពីការបះបោល អនាគតរបស់ក្រុមវ៉ាកនើ ចោទចំណោចបញ្ហា ពីរថ្ងៃបន្ទាប់ពីការបះបោលបរាជ័យរបស់ក្រុមយោធាប៉ារ៉ាវ៉ាកនើ នៅរុស្ស៊ី អនាគតនៃក្រុមទាហានស៊ីឈ្នួលនេះ និងមេដឹកនាំ លោកអេវហ្គេនី ព្រីកូហ្ស៊ី ចោទជាចំណោទបញ្ហា។

ដោយមិនមានការបង្ហាញទីតាំងដែលគាត់ស្នាក់នៅ លោកព្រីកូហ្ស៊ីន បានបញ្ជាក់កាលពីថ្ងៃចន្ទ ថា គោលដៅរបស់លោកគឺសង្គ្រោះក្រុមវ៉ាកនើ មិនមែនផ្តួលរំលំអំណាចរុស្ស៊ីទេ។

គោលដៅនៃក្បួនធ្វើដំណើរ គឺការពារមិនអនុញ្ញាតឲ្យបំផ្លាញក្រុមវ៉ាកនើ។ ពីរថ្ងៃបន្ទាប់ពីការបះបោលបរាជ័យ ប្រមុខក្រុមទាហានប៉ារ៉ា អេវហ្គេនី ព្រីកូហ្ស៊ីន បានចាកចេញពីភាពស្ងៀមស្ងាត់ កាលពីថ្ងៃចន្ទ ទី២៦ ។ នៅក្នុងសារមួយដែលមានរយៈពេល ១១នាទី លោកបានលើកបង្ហាញអំពីមូលហេតុនៃគំនិតផ្តួចផ្តើមខាងយោធាដ៏អស្ចារ្យនៅប្រទេសរុស្ស៊ី ដោយលោកបានអះអាងថា គោលដៅរបស់លោកមិនមែនផ្តួលរំលំអំណាចនៅក្នុងប្រទេសនោះទេ ប៉ុន្តែគឺដើម្បីការពារក្រុមទាហានស៊ីឈ្នួលរបស់លោក។

ការប៉ុនប៉ងបះបោររបស់ក្រុមទាហានប៉ារ៉ាវ៉ាកនើ បានបញ្ចប់កាលពីចុងសប្តាហ៍មុន តាមរយៈកិច្ចព្រមព្រៀងមួយរវាងលោកអេវហ្គេនី ព្រីកូហ្ស៊ីន និងវិមានក្រឹមឡាំង។ វាអនុញ្ញាតឲ្យប្រមុខកងទាហានស៊ីឈ្នួលទៅប្រទេសបេឡារុស ដោយសេរីភាព និងលើកលែងទោសចោលទាំងអស់ដែលដាក់លើរូបលោក និងអ្នកប្រយុទ្ធដែលដើរតាមលោក។ ជាថ្នូរមកវិញ ទាហានត្រូវតែត្រឡប់ចូលជំរុំវិញ។

ប៉ុន្តែវាលំបាក សព្វថ្ងៃនេះ នឹងដឹងអំពីអ្វីជាគោវាសនាដែលនឹងកើតមានឡើង ក្នុងរយៈពេលខ្លីខាងមុខរបស់ក្រុមទាហានស៊ីឈ្នួល និងប្រមុខរបស់ខ្លួននេះ។ លោក អ៊ុលរីច ប៊ូណាត ដែលជាអ្នកវិភាគខាងភូមិសាស្ត្រនយោបាយ និងជាអ្នកនិពន្ធសៀវភៅ សង្គ្រាមកូនកាត់នៅអ៊ុយក្រែន អះអាងថា ៖ «លោកអេវហ្គេនី ព្រីកូហ្ស៊ីន ពេលនេះ បានក្លាយជាគោលដៅរបស់វិមានក្រឹមឡាំង»។

នៅក្នុងសេចក្តីថ្លែងការណ៍ដែលប្រកាសដោយលោកវ្លាឌីមៀ ពូទីន បានចាត់ទុកលោកព្រីកូហ្ស៊ីនជាជនក្បត់ជាតិ និងជាភេរវករ។ ហើយប្រធានាធិបតីរុស្ស៊ីបាននិយាយជាច្រើនដងជាច្រើនសាថា ជនក្បត់ជាតិប្រព្រឹត្តិឧក្រិដ្ឋកម្មដ៏អាក្រក់។ ការបង្ហាញលោកអេវហ្គេនី ព្រីកូហ្ស៊ីន តាមរយៈពាក្យពេជន៍ជាសាធារណៈបែបនេះ គឺដូចជាការចុះហត្ថលេខាលើការឃាត់ខ្លួនសម្លាប់ដោយផ្ទាល់។

លោក អ៊ុលរីច ប៊ូណាត សង្កត់ធ្ងន់ថា ៖ «អ្វីដែលច្បាស់ គឺការបញ្ចប់របស់ក្រុមវ៉ាកនើនៅអ៊ុយក្រែន»។ បើយោងតាម លោក អ៊ុលរីច ប៊ូណាត ការបញ្ចប់ក្រុមវ៉ាកនើនៅអ៊ុយក្រែន និងនៅរុស្ស៊ី មិនមែនមានន័យថា ការបញ្ចប់វត្តមានរបស់ពួកគេនៅបរទេសនោះទេ មានជាអាទិ៍នៅលើទ្វីបអាហ្វ្រិក។ គ្មានអ្វីផ្លាស់ប្តូរនោះទេ ក្នុងរយៈពេលខ្លី និងមធ្យមទៅមុខ។ លោកអេវហ្គេនី ព្រីកូហ្ស៊ីន អាចនឹងស្ថាបនា មូលដ្ឋានរបស់ខ្លួននៅប្រទេសបេឡារុស និងបន្តដឹកនាំពីចម្ងាយនូវប្រតិបត្តិការ របស់ក្រុមលោកនៅអាហ្វ្រិក។

លោក អ៊ុលរីច ប៊ូណាត វិភាគថា ៖ «វាមានទំនាក់ទំនងដែលពឹងអាស្រ័យគ្នាទៅវិញទៅមុខរវាងក្រុមវ៉ាកនើ និងវិមានក្រឹមឡាំង នៅអាហ្វ្រិក។ ក្រុមវ៉ាក់នើ អាចឲ្យក្រុងមូស្គូទាញយកធនធានធម្មជាតិ បញ្ចៀសទណ្ឌកម្ម ឬជួយគាំទ្ររបៀបវារៈការទូតក្រុងមូស្គូ ដោយមិនចាំបាច់ប្រើឈ្មោះខ្លួន។ ជាការសងត្រឡប់ ទីក្រុងមូស្គូនឹងផ្តល់ឲ្យក្រុមនេះនូវមធ្យោបាយដឹកជញ្ជូន ផ្គត់ផ្គង់សម្ភារៈផ្សេងៗ និងអាវុធ»។

ដូច្នេះ ទោះបីជារឿងនេះមើលទៅផ្ទុយគ្នា វាអាចទៅរួច ដែលថា ទីក្រុងមូស្គូ វាយតម្លៃថា នឹងបន្តទំនាក់ទំនងជាមួយលោកព្រីកូហ្ស៊ីន ជាជាងបំផ្លាញលោក ដោយសារតែរឿងនេះអាចធ្វើឲ្យទីក្រុងមូស្គូអាចរក្សាប្រយោជន៍របស់ខ្លួនបាន៕



ប្រទេសលីបង់ នឹងបន្តរងគ្រោះដោយភាពអត់ឃ្លានកាន់តែធ្ងន់ធ្ងរ



អង្គការយូនីសេហ្វ បានអះអាងថា ស្ថានភាពនៃគ្រោះអត់ឃ្លានចំពោះកុមារនៅក្នុងប្រទេស លីបង់នៅពេលនេះកាន់តែមានស្ថានភាពអាក្រក់ទៅ។

អង្គការនេះបានអះអាងថា ជិត១ភាគ៣នៃកុមារលីបង់នៅពេលនេះកំពុងតែធ្លាក់ខ្លួននៅក្នុងគ្រោះអត់ឃ្លានកាន់តែអាក្រក់បំផុត។

ប្រភពដដែលបានរាយការណ៍ថា នៅពេលនេះស្ថានភាពនៃបញ្ហានៅក្នុងប្រទេសលីបង់កាន់តែអាក្រក់ឡើង ដោយគ្រួសារ៩ នៅក្នុងចំណោម១០ គ្រួសារគឺកំពុងតែស្ថិតនៅក្នុងស្ថានភាពខ្វះមូលដ្ឋានចាំបាច់សម្រាប់ជីវិតជាពិសេសគឺអាហារ ។

ប្រភពដដែលបានបន្តថា ក្រៅពីកុមារ ស្ត្រីដែលមិនអាចទទួលបានរបស់របរប្រើប្រាស់ជាពិសេស គឺអនាម័យ គឺមានរហូតដល់ ទៅ ៥១ ភាគរយ ដែលនាំអោយកូនៗរបស់ពួកគេកាន់តែមានបញ្ហាអាក្រក់បន្ថែមទៀត។

ប្រភពដដែលបានបន្តថា ដើម្បីរស់ មានគ្រួសារជាច្រើននៅក្នុងប្រទេសនេះ បានបញ្ជូនកុមារាកុមារី ទៅធ្វើការនៅឆ្ងាយៗពីផ្ទះដើម្បីជួយរកប្រាក់ចំណូលដោះស្រាយជីវភាព ដែលកំពុងតែជួបបញ្ហា៕



# អ្នកជំនាញ៖ យុវជនកម្ពុជា គួរសិក្សាជំ... បច្ចេកវិទ្យាឌី... ដើម្បីទទួលបានឱកាស...

*អត្ថបទ៖ ម៉ូត ពេជ្រហ្សាលីន*

ចាប់តាំងពីវិបត្តិជំងឺកូវីដ-១៩ នៅកម្ពុជា ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលមានសន្ទុះកាន់តែខ្លាំងក្នុងវិស័យសាធារណៈ វិស័យឯកជន និងក្នុងចំណោមប្រជាពលរដ្ឋទូទៅ ពិសេសសិស្ស-និស្សិត។ បដិវត្តឧស្សាហកម្មជំនាន់ទី៤ បានធ្វើឱ្យការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលកាន់តែមានលក្ខណៈចាំបាច់ និងទូលំទូលាយក្នុងគ្រប់វិស័យ រួមចំណែកជំរុញកំណើនសេដ្ឋកិច្ច។

ដោយមើលឃើញពីគុណតម្លៃនៃវិស័យនេះ អ្នកជំនាញបានជំរុញឱ្យយុវជន ពិសេសសិស្សានុសិស្សកម្ពុជា គួរចាប់យកជំនាញជំនាញបច្ចេកវិទ្យាឌីជីថល ដើម្បីពង្រឹងសមត្ថភាពខ្លួនពិសេសទទួលបានឱកាសការងារល្អថែមទៀត។

ការលើកឡើង និងជំរុញនេះ គឺធ្វើឡើងស្របពេលដែលការប្រឡងមធ្យមសិក្សាទុតិយភូមិសម្រាប់ឆ្នាំសិក្សា ២០២១- ២០២២ ទើបតែបានបញ្ចប់ថ្មីៗ ដើម្បីធ្វើជាត្រីវិស័យជួយតម្រង់ទិសដល់សិស្សានុសិស្សអាចជ្រើសរើសជំនាញសិក្សាបានត្រឹមត្រូវ និងស្របតាមទីផ្សារការងារបច្ចុប្បន្ន។

ករណីនេះ ត្រូវបានលោក ពេជ្រ រិទ្ធី មន្ត្រីជាន់ខ្ពស់នៃអាជ្ញាធរនិយ័តករមូលបត្រកម្ពុជា បានលើកទឹកចិត្តដល់សិស្សានុសិស្ស ចាប់យកជំនាញបច្ចេកវិទ្យាឌីជីថល ដើម្បីអាចអភិវឌ្ឍប្រទេសឆ្ពោះទៅរកសេដ្ឋកិច្ចឌីជីថល និងបដិវត្តឧស្សាហ កម្មជំនាន់ទី៤ ។

លោក ពេជ្រ រិទ្ធី បានលើកឡើងថា នៅក្នុងយុគសម័យឌីជីថល បច្ចេកវិទ្យាបានដើរតួនាទីយ៉ាងសំខាន់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ការធ្វើធុរកិច្ច និងការផ្តល់សេវាសាធារណៈនិងសេវាផ្សេងៗ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

លោកបានរៀបរាប់បន្ថែមដូច្នេះថា ៖ «ខ្ញុំសូមអំពាវនាវនិងលើកទឹក ចិត្តដល់ក្មួយៗសិស្សានុសិស្សទាំងអស់ បន្ទាប់ពីទទួលបានលទ្ធផលជាប់ជាស្ថាពរ សូមពិចារណាចាប់យកការសិក្សាជំនាញផ្នែកបច្ចេកវិទ្យាឌីជីថល និងជំនាញពាក់ព័ន្ធ ដើម្បីពង្រឹងសមត្ថភាព ទទួលបានឱកាសការងារល្អមានប្រាក់ចំណូលខ្ពស់សម្រាប់លើកកម្ពស់ជីវភាពគ្រួសារ និងចូលរួមចំណែកសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការកសាងរដ្ឋាភិបាល សេដ្ឋកិច្ច និងសង្គមឌីជីថលដ៏រស់រវើក»។

> ទោះបីយើងជ្រើសរើសយកមួយណាក៏ដោយ បើយើងមានសេចក្តីស្រឡាញ់ពិត ជម្រើសរបស់យើងមិនខុសទេ។ កុំឲ្យខ្លួនឯងបិទបេះដូងមិនហ៊ានទទួល ខ្លាចបរិយាកាសជុំវិញខ្លួន។ កុំខ្លាច! បើព្រះជាម្ចាស់ត្រាស់ហៅហើយ សូមទៅ។ ពេលទៅ ព្រះជាម្ចាស់នឹងត្រួសត្រាយផ្លូវឲ្យ ហើយ អំណរសប្បាយនោះនឹងមាន

លោកក៏បានបង្ហាញក្តីជឿជាក់ដែរថា បន្ទាប់ពី






ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា។

តាមការសិក្សាស្រាវជ្រាវមានហេតុផលជាច្រើននាពេលកន្លងមក ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានលើកយកហេតុផលសំខាន់ៗចំនួន៥ ដែលជំរុញឱ្យនិស្សិតជ្រើសរើសសិក្សាជំនាញពាក់ព័ន្ធបច្ចេកវិទ្យាឌីជីថល។

ហេតុផលទាំងនោះរួមមាន ការទទួលបានប្រាក់បៀវត្សខ្ពស់ និងទីផ្សារការងារមានតម្រូវការច្រើន៖ បច្ចេកវិទ្យាឌីជីថល បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ហើយគ្រប់ស្ថាប័ន និងក្រុមហ៊ុនទាំងអស់ពិតជាត្រូវការអ្នកជំនាញបច្ចេកវិទ្យាឌីជីថល ដើម្បីជួយសម្រួលដល់ការងារឱ្យកាន់តែមានប្រសិទ្ធភាព។

រីឯហេតុផលទី២ គឺបើកអាជីវកម្មដោយខ្លួនឯង៖ នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ អ្នកប្រកបអាជីវកម្មលើវិស័យបច្ចេកវិទ្យាឌីជីថលនៅមានចំនួនតិច ដូច្នេះ អ្នកមានជំនាញផ្នែកនេះ អាចខិតខំប្រឹងប្រែងដើម្បីប្រែក្លាយពីអ្នកជំនាញទៅជាម្ចាស់អាជីវកម្ម ឬអ្នកបង្កើតធុរកិច្ចថ្មីឌីជីថល (Startup) តាមរយៈការផ្ដល់សេវាកម្មថ្មី ប្លែក ហើយថែមទាំងងាយស្រួលចូលទីផ្សារផងដែរ។ បច្ចុប្បន្ននេះ ឱកាសអាជីវកម្មនៅក្នុងវិស័យបច្ចេកវិទ្យាឌីជីថលនៅមានច្រើន បើធៀបនឹងអាជីវកម្មប្រពៃណីដែលមានស្រាប់។

ចំណែកហេតុទី៣គឺមានការផ្ដល់អាហារូបករណ៍ជាច្រើន៖ ដើម្បីរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និងបរិវត្តកម្មឌីជីថលនៅកម្ពុជា មានអាហារូបករណ៍ជាច្រើនផ្ដល់ជូនដល់សិស្សានុសិស្សដើម្បីបន្តចូលរៀនមហាវិទ្យាល័យលើជំនាញបច្ចេកវិទ្យាឌីជីថល។

ជាក់ស្ដែង «កម្មវិធីអាហារូបករណ៍ទេពកោសល្យឌីជីថលតេជោ (Techo Digital Talent Scholarship)» តាមរយៈក្រសួងប្រៃសណីយ៍ បានផ្ដល់ជូនការសិក្សា ជំនាញបច្ចេកវិទ្យាឌីជីថល ដល់សិស្សឆ្នើមរហូតដល់




៥០០កន្លែង ជារៀងរាល់ឆ្នាំ សម្រាប់សិក្សាថ្នាក់បរិញ្ញាបត្រនៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន ដោយនិស្សិតអាហារូបករណ៍ម្នាក់ៗ ទទួលបានកុំព្យូទ័រយួរដៃ១គ្រឿង ការរ៉ាប់រងលើថ្លៃសិក្សា ប្រាក់ឧបត្ថម្ភលើការស្នាក់នៅ និងហូបចុកសម្រាប់រយៈពេល៤ឆ្នាំ។

សម្រាប់ហេតុផលទី៤ គឺមុខវិជ្ជាមានប្រយោជន៍ និងគួរចាប់អារម្មណ៍ជាច្រើន៖ ការជ្រើសរើសជំនាញបច្ចេកវិទ្យាឌីជីថល គឺមានការបារម្ភថាមានមុខវិជ្ជាពិបាកក្នុងការសិក្សា។ ផ្ទុយទៅវិញមាននិស្សិតជាច្រើនក្រោយបានចូលរៀនជំនាញនេះ ពួកគេបានសម្ដែងនូវការសប្បាយរីករាយ




និងចាប់អារម្មណ៍ខ្លាំងលើមុខវិជ្ជាដែលពួកគេរៀន ដោយសារតែមុខវិជ្ជាភាគច្រើនផ្ដល់នូវពុទ្ធិថ្មីៗ ដូចជាការដោះស្រាយបញ្ហា និងរបកគំហើញថ្មីៗមិនធ្លាប់មានជាដើម។

ហេតុផលចុងក្រោយគឺ ចូលរួមលើកកម្ពស់សេដ្ឋកិច្ចកម្ពុជាឱ្យមានវឌ្ឍនភាពឈានទ្បើង៖ បច្ចេកវិទ្យាឌីជីថលបានដើតួរយ៉ាងសកម្មក្នុងការប្រែក្លាយ និងជំរុញសកម្មភាពពាណិជ្ជកម្ម ប្រតិបត្តិការធុរកិច្ច ប្រព័ន្ធផ្សព្វផ្សាយ ការទទួលបានសេវាហិរញ្ញវត្ថុ និងសេវាកម្សាន្តជាច្រើនផ្សេងទៀត។

សូមបញ្ជាក់ដែរថា បើតាមក្រសួងប្រៃសណីយ៍ ជំនាញពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថលមានដូចជា វិទ្យាសាស្ត្រកុំព្យូទ័រ (Computer Science), ទូរគមនាគមន៍និងបណ្ដាញ (Telecoms and Networking), បច្ចេកវិទ្យាក្លោដ (Cloud Computing), ការអភិវឌ្ឍសុសវែរ (Software Development)។ វិទ្យាសាស្ត្រទិន្នន័យ (Data Science), សន្តិសុខសាយប័រ (Cybersecurity), បច្ចេកវិទ្យាប្លុកឆេន (Block Chain), បច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech), បច្ចេកវិទ្យាបញ្ញាសប្បនិមិត្ត (AI) និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce)៕




## តើយុវជនត្រូវត្រៀមខ្លួនដូចម្ដេច ដើម្បីសម្របខ្លួនក្នុងយុគ្គសម័យបច្ចេកវិទ្យា?

នាយកដ្ឋានព័ត៌មានវិទ្យា បានឱ្យដឹងថា យុវជនកម្ពុជា កំពុងទទួលយកនូវចំណេះដឹងថ្មីៗអំពីបច្ចេកវិទ្យា ក្នុងគោលបំណងពង្រីកពុទ្ធិចំណេះជំនាញ និងចំណេះដឹងទូទៅ ដើម្បីឲ្យដើរទាន់បរិបទនៃសង្គមបច្ចេកវិទ្យាក្នុងប្រទេស ក៏ដូចជានៅក្នុងតំបន់ផងដែរ។

ដើម្បីត្រៀមខ្លួនប្រកួតប្រជែងក្នុងទីផ្សារការងារ និងចូលរួមអភិវឌ្ឍជាតិ យុវជនកម្ពុជាគប្បី៖ បន្តខិតខំពង្រឹង និងក្រេបជញ្ជក់ចំណេះដឹងមូលដ្ឋាន (ថ្នាក់មធ្យមសិក្សា និងឧត្តមសិក្សា), បន្តខិតខំពង្រឹងចំណេះដឹងជំនាញវិជ្ជាជីវៈ ឯកទេស បន្តអនុវត្តដើម្បីបង្កើនប្រសិទ្ធភាពការងារ និងជួសជុលចំណុចខ្វះខាត (បទពិសោធន៍)។

បន្តខិតខំសិក្សាពង្រឹងចំណេះដឹងភាសាបរទេស (តួយ៉ាង ភាសាអង់គ្លេស), បន្តចូលរួមអភិវឌ្ឍសហគមន៍ តាមរយៈការចែករំលែកចំណេះដឹង និងបទពិសោធន៍, បន្តប្រកាន់យកនូវសេចក្ដីថ្លៃថ្នូរ សីលធម៌ សុជីវធម៌ សាមគ្គីភាព ក្នុងការប្រតិបត្តិក្នុងគ្រួសារ សហគមន៍ និងប្រទេសជាតិ, ប្រកាន់ទំលាប់អាន ទំលាប់សិក្សាស្រាវជ្រាវ និងទំលាប់ចែករំលែក៕



# គ្រីស្តបរិស័ទ៣ភូមិភាគគោរពមរណសាក្សីនៅកម្ពុជា

*អត្ថបទ៖ ចាន់ ម៉ានុត*

លោកអភិបាលទាំងបីភូមិភាគ លោកបូជាចារ្យ និងគ្រីស្តបរិស័ទជិត៣០០០នាក់ពីគ្រប់ភូមិភាគ បានជួបជុំគ្នានៅលើដីមរណសាក្សីកាលពី ថ្ងៃទី១៧ ខែមិថុនា ដើម្បីរំឭកអំពីវីរភាពរបស់អស់លោក ដែលបានបូជាជីវិតក្នុងរបបប្រល័យពូជសាសន៍ ដោយសារតែជំនឿ។

កម្មវិធីនេះបានប្រព្រឹត្តទៅនៅព្រះសហគមន៍ តាំងគោក ស្ថិតក្នុងស្រុកតាំងគោក ក្នុងខេត្តកំពង់ធំដែលជាចំណុចកណ្តាលនៃប្រទេសកម្ពុជាមានចម្ងាយប្រមាណ១០០គីឡូម៉ែត្រពីរាជធានីភ្នំពេញ។

ព្រះសហគមន៍នៅកម្ពុជាបានចាប់ផ្តើមរំឭកខួបនេះតាំងពីឆ្នាំ២០០០ ពោលគឺក្រោយសង្គ្រាមស៊ីវិលបានបញ្ចប់ និងប្រទេសមានសន្តិភាពឡើងវិញ ដោយរឭកដល់អស់អ្នកដែលបានបូជាជីវិតដោយសារជំនឿ។

ថ្លែងនៅក្នុងធម្មទេសនា លោកអភិបាល អូលីវីយេ ជ្មីតហស្លេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានប្រសាសន៍ថា ទឹកដីតាំងគោកនេះមិនមែនជាដីធម្មតាទេ គឺពោរពេញដោយបារមី ដោយនៅទីនេះមានវត្ថុស័ក្តិសិទ្ធ២ គឺគ្រែដែលលោក ឆ្មារ សាឡាស់ ថ្វាយអភិបូជារហូតដល់គាត់បានទទួលមរណភាពនៅឆ្នាំ១៩៧៦ ជាគ្រែដែលមានជីវិត។

បច្ចុប្បន្នគ្រែនេះត្រូវបានរក្សាទុកនៅក្នុងទឹកដីនៃព្រះសហគមន៍តាំងគោក ជាទីកន្លែងដែលលោកអភិបាលយ៉ូសែប ឆ្មារ សាឡាស់និងសហការីត្រូវបានជម្លៀសពីភ្នំពេញតាមគោលដៅរបស់អង្គការខ្មែរក្រហម។ លោកនិងសហការី ដែលមានលោកយ៉ូសែប ឆ្មារ សាឡឹម ដែលត្រូវជាប្អូន លោកទ្រឿង សំរើន បានរស់នៅនិងថ្វាយអភិបូជារៀងរាល់ថ្ងៃ ដោយលាក់កំបាំងពីភ្នែករបស់ឈ្លប។

គ្រែនេះ ត្រូវបានថែរក្សាទុក ដើម្បីគោរព និងរំឭកដល់អស់លោកដែលបានថ្វាយអភិបូជា ហើយត្រូវបានស្លាប់និងត្រូវបានគេសម្លាប់ក្នុងរបបវាលពិឃាត។

លោកអភិបាលអូលីវីយេ បន្ថែមថា វត្ថុទី២គឺបន្ទោងឈើឆ្កាង ដែលត្រូវបានបញ្ជូនបន្តពីលោក



អភិបាលមួយជំនាន់ទៅមួយជំនាន់ ហើយពេលនេះលោកកំពុងថែរក្សានិងគ្រប់គ្រង។

បន្ទោងឈើឆ្កាងរបស់លោកអភិបាលនេះ បានបន្តជូនមកលោកអភិបាលនៅកម្ពុជាចំនួន ៦ជំនាន់មកហើយ ដែលធ្វើអំពីមាស ហើយបានបញ្ជូនបន្តដល់លោកអភិបាលឆ្មារ សាឡាស់ ក្នុងពិធីតែងតាំងជាអភិបាល កាលពីថ្ងៃទី១៤ មេសា ១៩៧៥ មុនពេលរបបប្រល័យពូជាសាសន៍ប៉ុលពតបានចាប់ផ្តើមតែ៣ថ្ងៃប៉ុណ្ណោះ។

អតីតអភិបាលព្រះសហគមន៍ខ្មែរដំបូងគេរូបនេះ បានរក្សាទុកវានៅក្រោមសំបុកមាន់ ដើម្បីចៀសពីការរុករករបស់ពួកខ្មែរក្រហម ដែលគេហៅថា «អង្គការ»។ ក្រោយពេលលោកស្លាប់ ម្តាយរបស់លោកបានរក្សាវាទុក ហើយបំពាក់បន្តជូនលោកអភិបាលអេមីល ដេតម្ប ហើយមកដល់ពេលនេះ គឺលោកអភិបាលអូលីវីយេ ជ្មីតហស្លេ។

លោកអភិបាលអូលីវីយេ បន្ថែមថា យើងជឿថាពេលវត្ថុទាំងពីរជួបគ្នា គឺជាបារមីរបស់ព្រះជាម្ចាស់ដ៏ពេញលក្ខណៈដែលគង់នៅជាមួយយើង ណែនាំឱ្យយើងមានសេចក្តីសុខ ណែនាំឱ្យយើងមានកម្លាំង ណែនាំឱ្យដឹងថាពិតមែនព្រះអំណោយទានព្រះជាម្ចាស់គង់នៅជាមួយយើង។

លោកអភិបាលបានណែនាំឲ្យអ្នកចូលរួមទាំងអស់ នឹកដល់ព្រះបន្ទូលព្រះជាម្ចាស់ដែលថា «បើអ្នកណាចង់បម្រើខ្ញុំ អ្នកនោះត្រូវមកតាមខ្ញុំ ខ្ញុំនៅទីណាអ្នកបម្រើរបស់ខ្ញុំនឹងនៅទីនោះដែរ អ្នកណាបម្រើខ្ញុំ ព្រះបិតានឹងលើកកិត្តិយសអ្នកនោះ»។

លោកបន្ថែមថា ព្រះបន្ទូលនេះ ណែនាំឲ្យយើងជាអ្នកបម្រើរបស់ព្រះជាម្ចាស់អាចទទួលជីវិតថ្មីជាមួយព្រះអង្គ ហើយជាពេលវេលាដើម្បីអរព្រះគុណព្រះជាម្ចាស់ លើទឹកដីមរណសាក្សីដែលណែនាំឱ្យព្រះសហគមន៍មានជីវិត។

«នេះជាលើកទីមួយសម្រាប់ខ្ញុំដែលបានមកចូលរួមកម្មវិធីគោរពមរណសាក្សីនៅទីនេះហើយខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់សម្រាប់ពេលវេលាដ៏មានតម្លៃមួយនេះ»នេះជាសម្តីរបស់លោកព្រិច ជុន អាយុ៥០ឆ្នាំ ជាគ្រីស្តរិស័ទមកពីព្រះសហគមន៍មណ្ឌលគិរីនៃភូមិភាគកំពង់ចាម។

លោកព្រិច ជុន វ័យ៥២ឆ្នាំមានប្រសាសន៍ថា ថ្ងៃនេះលោកពិតជាមានអំណរសប្បាយដែលបានចូលរួមកម្មវិធីនេះជាលើកទីមួយ។ លោកបន្ថែមថា លោកពិតជាមានមោទនភាពដែលព្រះសហគមន៍កាតូលិកនៅកម្ពុជាមានលោកអភិបាល លោកបូជាចារ្យជាអ្នកគង្វាលដែលបានជួយការពារព្រះសហគមន៍នៅសម័យនោះ។

លោកបន្តទៀតថា តាមរយៈគំរូនិងឈាមរបស់មរណសាក្សីគឺពិតជាជួយដាស់តឿនដល់ជំនឿរបស់យើងជាគ្រីស្តបរិស័ទ។ លោកថា ដំបូងឡើយលោកគិតថា មានតែជនជាតិបរទេសទេដែលមានជំនឿលើព្រះជាម្ចាស់ ប៉ុន្តែឥលូវនេះ យើងមានលោកអភិបាលជាជនជាតិខ្មែរទៀតគឺហាក់ដូចជាដាស់តឿនឱ្យគ្រីស្តបរិស័ទមានជំនឿកាន់តែរឹងមាំ និងផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់។

លោកស្រី ហួត ហ៊ាង អាយុ៦៩ឆ្នាំ ជាគ្រីស្តបរិស័ទមកពីព្រះសហគមន៍កោះរការក្រៅនៃភូមិភាគកំពង់ចាម បានឱ្យដឹងថា កម្មវិធីថ្ងៃនេះធ្វើឱ្យគាត់នឹកដល់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ឲ្យយើងទៅជាមរណសាក្សី ហើយព្រះជាម្ចាស់គង់នៅជាមួយយើង និងប្រទានព្រះពរឱ្យយើងរហូត។

លោកស្រីហ៊ាង បន្តថា ការសម្តែងរឿងអំពីជីវិតមរណសាក្សីនៅសម័យប៉ុលពត ធ្វើអោយគាត់សឹងតែស្រក់ទឹកភ្នែក ដោយនឹកឃើញថា អំពីរបៀបដែលគ្រីស្តបរិស័ទសម័យនោះបានរក្សាជំនឿ។

«នោះមានលោកបូជាចារ្យ បងប្អូនគ្រីស្តបរិស័ទលាក់លៀមពីភ្នែកអង្គការដើម្បីទទួលព្រះកាយជាសញ្ញាសម្គាល់មួយថា ទោះបីជាស្ថិតនៅក្នុងស្ថានភាពបែបណាក៏ព្រះជាម្ចាស់គង់នៅជាមួយយើងជានិច្ច។» អ្នកស្រីហ៊ាងបន្ថែម។

ព្រះសហគមន៍កាតូលិកនៅកម្ពុជា បានរៀបចំឯកសារជាច្រើន ដោយចាត់ឲ្យមានតុលាការមរណសាក្សីផង ដើម្បីសើររើនិងចងក្រងឯកសារពាក់ព័ន្ធនានាដល់អ្នកដែលបានស្លាប់ដោយសារជំនឿក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត ពីឆ្នាំ ១៩៧៥-១៩៧៩។

ក្នុងរបប៣ឆ្នាំ៨ខែ២០ថ្ងៃ ប្រទេសកម្ពុជាត្រូវបានបំផ្លាញ ទាំងហេដ្ឋារចនាសម្ព័ន្ធជាតិ សាសនា និងធនធានមនុស្ស។ ព្រះសហគមន៍កាតូលិក ក៏ដូចជាសាសនាឯទៀត បានរងការបំផ្លិចបំផ្លាញស្ទើរគ្មានសល់ ហើយគ្រីស្តបរិស័ទនិងក្រុមអ្នកបួសជាច្រើនបានស្លាប់និងត្រូវបានសម្លាប់ ដោយរួមជាប្រជាជនខ្មែរជិត២លាននាក់។

លោកបូជាចារ្យប៉ូល រឿង ឆ័ត្រសិរី ជាអ្នករៀបចំឯកសារនានា ឲ្យដឹងថា ក្នុងពេលនេះ មានបក្ខភាពអ្នកបម្រើព្រះជាម្ចាស់ចំនួន១៤រូបដែលកំពុងសិក្សា និងស្រាវជ្រាវលើប្រវត្តិរូប និងចងកងជាឯកសារសម្រាប់ដាក់ទៅកាន់សន្តអាសនៈ ដើម្បីស្នើសុំអស់លោកក្លាយជាមរណសាក្សីសម្រាប់ព្រះសហគមន៍នៅកម្ពុជា ដែលក្នុងនោះរួមមាន លោកបូជាចារ្យនិងបព្វជិតចំនួន៧រូប ដូនជីចំនួន២រូប លោកអភិបាលចំនួន២រូប និងគ្រហស្ថចំនួន៣រូប៕

# លោកអូលីវីយេ៖ នេះជាលើកទី១ និងចុងក្រោយ ដែលយើងទទួលព្រះកាយព្រះគ្រីស្ត

*អត្ថបទ៖ សួន ស្រីហួច ដាលីស*

«នៅពេលដែលយើងទទួលព្រះកាយ សូមឱ្យយើងនឹកថាជាលើកទីមួយដែលយើងទទួលព្រះកាយព្រះគ្រីស្តនៅក្នុងជីវិត ដែលជាព្រះកាយតែមួយ និងជាថ្ងៃចុងក្រោយដែលយើងទទួលព្រះកាយព្រះគ្រីស្ត។»



នេះជាប្រសាសន៍របស់លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញក្នុងឱកាសបុណ្យគោរពព្រះកាយនិងព្រះលោហិតព្រះគ្រីស្ត នាថ្ងៃទី១១ មិថុនានៅព្រះវិហារព្រះកុមារយេស៊ូបឹងទំពុននាររាជធានីភ្នំពេញ។

លោកអភិបាលអូលីវីយេ ផ្មឹតហាស្លេបន្ថែមថា ធ្វើយ៉ាងនេះ គឺដើម្បីឲ្យយើងខិតខំរស់នៅអស់ពីសេចក្តីស្រឡាញ់ និងធ្វើជាសាវ័ករបស់ព្រះយេស៊ូគ្រីស្ត។

ក្នុងថ្ងៃនោះដែរ លោកអភិបាលព្រះសហគមន៍បានផ្តល់អគ្គសញ្ញាលាបថ្វាសដល់បេក្ខជន១៦នាក់ និង១៣នាក់ផ្សេងទៀតទទួលអគ្គសញ្ញាព្រះកាយព្រះគ្រីស្តលើកដំបូង។





លោកអភិបាលអូលីវីយេមានប្រសាសន៍ថា ព្រះកាយព្រះគ្រីស្តនាំឲ្យយើង ក្លាយជាគ្រួសារតែមួយដែលមានព្រះយេស៊ូជាសិរសា យើងអាចនិយាយគ្នាទៅវិញទៅមក យល់ចិត្តគ្នា និងលើកលែងទោសឱ្យគ្នាទៅវិញទៅមក ទោះបីជាពិភពលោកសង្គម និងគ្រួសាររបស់យើងបាក់បែកគ្នាក៏ដោយ។

លោកបន្ថែមថា យើងរស់នៅក្នុងសង្គមសម្ភារនិយមខ្លាំងពិតមែន ប៉ុន្តែព្រះកាយនាំឱ្យយើងចិញ្ចឹមជីវិតពោរពេញដោយសុភមង្គលដ៏ពិតប្រាកដ ខុសពីម្ហូបអាហាររាល់ថ្ងៃដែលនាំឱ្យយើងមានជំងឺផ្សេងៗ និងបានជួយយើងឲ្យរកឃើញការសង្គ្រោះ។

សង្គមបច្ចុប្បន្នមានការស្អប់គ្នានិងមានសង្គ្រាម ប៉ុន្តែព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធជួយយើងកសាងពិភពថ្មីដ៏ពិតប្រាកដចាកឆ្ងាយអំពីការស្អប់និងអំពើហិង្សា។

ព្រះកាយព្រះគ្រីស្តដែលយើងទទួលទាន គឺនឹងនាំយើងឲ្យមានសង្ឃឹម និងមានជីវិតអស់កល្បជានិច្ច។

ម៉ារីវិន ពិសី ទទួលអគ្គសញ្ញាលាបថ្វាសនៅថ្ងៃនេះ ឲ្យដឹងថា «ព្រះវិញ្ញាណដល់វិសុទ្ធបានជួយលើកទឹកចិត្តខ្ញុំ ឱ្យមានទំនុកចិត្តក្នុងជំនឿកាន់តែរឹងមាំ និងជួយណែនាំខ្ញុំឱ្យប្រកាសដំណឹងល្អទៅកាន់អ្នកដទៃ... ហើយចេះប្រកាសថា ខ្ញុំជាគ្រីស្តបរិស័ទ ជាកូនរបស់ព្រះជាម្ចាស់ និងព្រះជាម្ចាស់ស្រឡាញ់ខ្ញុំហើយខ្ញុំក៏ស្រឡាញ់ព្រះអង្គ»។

ពិសីដែលពេលនេះ កំពុងបម្រើក្នុងក្រុមចម្រៀងបាននិយាយទៀតថា នាងនឹងប្រាប់មិត្តភក្តិដែលជាពុទ្ធិបរិស័ទឱ្យពួកគេយល់ថា ព្រះជាម្ចាស់ស្រឡាញ់មនុស្សគ្រប់គ្នានិងអ្នកណាក៏អាចក្លាយជាកូនរបស់ព្រះអង្គបាន។

«ខ្ញុំអធិដ្ឋានរាល់យប់ និងមកព្រះវិហារឱ្យបានរាល់អាទិត្យដើម្បីបង្ហាញថា ខ្ញុំជាគ្រីស្តបរិស័ទ។» នេះជាការបញ្ជាក់របស់យ៉ូសែប វិនឡេង អាយុ១៤ ឆ្នាំ។

វិនឡេង ក៏ដូចជាយុវតីខាងលើដែរ ដែលរស់នៅក្នុងសង្គមដែលមានទំនាក់ទំនងភាគច្រើនជាមួយពុទ្ធបរិស័ទដែលជាមិត្តរួមថ្នាក់របស់ខ្លួន។

ឡេងបន្តថា «ខ្ញុំគិតថាព្រះវិញ្ញាណដ៏វិសុទ្ធអស្ចារ្យ អាចធ្វើឱ្យខ្ញុំមានភាពក្លាហានទៅប្រកាសដំណឹងល្អដល់មិត្តភក្តិរបស់ខ្ញុំនៅសាលារៀនដែលជាពុទ្ធបរិស័ទ»។

វេងវឿន ស៊ីម៉ូនករុណា វ័យ ១២ ឆ្នាំ សព្វថ្ងៃជាសមាជិកក្រុមចម្រៀងនិងបម្រើអាសនៈ បានឲ្យដឹងថា គាត់នឹងធ្វើយ៉ាងណាដើម្បីឱ្យមានការប្រាស្រ័យទាក់ទងគ្នាជាមួយក្រុម ជាលក្ខណៈបងប្អូនតែមួយ។

ស៊ីម៉ូនករុណា បន្ថែមថា «យើងក៏អាចអធិដ្ឋានឱ្យគ្នាទៅវិញទៅមកដើម្បីផ្តល់សេចក្តីសុខឱ្យគ្នា និងចែករំលែកអំពីអ្វីដែលយើងមានទៅកាន់អ្នកដទៃទៀត ដើម្បីឱ្យពួកគេអាចយកបទពិសោធពីយើងទៅអនុវត្តនៅក្នុងជីវិតរបស់ពួកគេ។»

យុវិនរូបនេះបន្ថែមថា ប្រសិនបើមានពេល គាត់នឹងចូលរួមអប់រំជំនឿដើម្បីឱ្យព្រះសហគមន៍មានជីវិតបន្តទៅមុខយ៉ាងរលូន៕

# ព្រះសហគមន៍ចំការទៀងរៀបចំកម្មវិធីសិទ្ធិកុមារសម្រាប់កុមារ៦០០នាក់

*អត្ថបទ៖ ចាន់ ម៉ានុត*

កុមារជាង ៦០០នាក់ ដែលរស់នៅក្នុងឃុំគូសភាគច្រើនជាកុមារកាយឫទ្ធិរបស់ព្រះសហគមន៍ បាននាំគ្នាមកចូលរួមទិវាកុមារអន្តរជាតិ ដែលរៀបចំឡើងដោយព្រះហសគមន៍សន្តីម៉ារីញញឹមចំការទៀង ស្ថិតក្នុងភូមិចំការទៀង ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ ប្រមាណជា៨០គីឡូម៉ែត្រពីរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែមិថុនា កន្លងទៅ។

លោកអភិបាលអូលីវីយេ ផ្មឹតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ជាអធិបតីក្នុងកម្មវិធីនេះ មានប្រសាសន៍ថា កុមារទាំងអស់ត្រូវមានឪពុកម្តាយថែរក្សានិងស្រលាញ់ មានសិទ្ធិទៅរៀននៅសាលាជាប្រចាំ ទទួលទានអាហារគ្រប់គ្រាន់ អាចទៅព្យាបាលជំងឺនៅមន្ទីរពេទ្យ មានកន្លែងស្នាក់នៅត្រឹមត្រូវ និងមានសិទ្ធិចូលរួមកម្មវិធីសប្បាយរីករាយ។

លោកបន្តថា ទោះបីមិនមែនជាបុណ្យណ្យអែល ប៉ុន្តែថ្ងៃ១មិថុនាក៏ជាពេលវេលាមួយសំខាន់ ដែលយើងរំឭកដល់សិទ្ធិកុមារទាំងអស់នៅលើពិភពលោក។ យើងសូមអរព្រះគុណព្រះជាម្ចាស់ដែលបានប្រមូលកុមារជាង៦០០នាក់មកចូលរួម។

កម្មវិធីនេះដែរ កុមារទាំងអស់បានលែងកំសាន្តជាមួយគ្នា និងទទួលបានសម្ភារលេងនិងនំមួយចំនួន ដើម្បីទទួលអំណរសប្បាយរួមគ្នា។

ជារៀងរាល់ថ្ងៃអាទិត្យ ព្រះសហគមន៍កាតូលិកចំការទៀងបានរៀបចំកម្មវិធីសម្រាប់កុមារកាយឫទ្ធិដែលមានចំនួន៦០-៨០នាក់ ដោយអប់រំពួកគាត់អំពីសុជីវធម៌ របៀបអនាម័យ អំពីការអត់ទោស និងស្រលាញ់ សាមគ្គីគ្នាទៅវិញមក។



លោក គឿន សុភ័ណ្ឌ ជាអ្នកទទួលខុសត្រូវកាយរិទ្ធនៅព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀង បានឱ្យដឹងដែរថា រៀងរាល់ថ្ងៃអាទិត្យមានការជួបជុំគ្នា១ម៉ោងដើម្បីបង្រៀនមេរៀនទាក់ទងជាមួយសៀវភៅរបស់ការិយាល័យយុវជនភូមិភាគភ្នំពេញ មានដូចជាការផាត់ពណ៌ ការលេងហ្គេមកំសាន្តសប្បាយ ការអប់រំទាក់ទងទៅនឹងវិន័យក្នុងក្រុមគ្រួសារ នៅសាលារៀន និងជាមួយបរិស្ថាន។

ព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀងនៃមណ្ឌលសកម្មភាពតាកែវ មានសកម្មភាពជាច្រើន ដូចជាកម្មវិធីអប់រំចំណេះទូទៅពីមត្តេយសិក្សាដល់មធ្យមសិក្សា កម្មវិធីកុមារកាយឫទ្ធិ សិល្បៈនិងវប្បធម៌ សហគ្រិនសង្គម មណ្ឌលមើលថែកុមារមានពិការភាព និងមានសកម្មភាពចុះសួរសុខទុក្ខចាស់ជរា និងអ្នកក្រីក្រតាមភូមិ កម្មវិធីអប់រំជំនឿជាដើម៕

# ២៥ឆ្នាំជាពេលត្រូវអរព្រះគុណព្រះជាម្ចាស់ និងបន្តដំណើរទៅមុខ

*អត្ថបទ៖ សួន ស្រីហួច ដាលីស*

កិច្ចការប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់លើទឹកដីកម្ពុជាក្នុងរយៈពេល២៥ឆ្នាំរបស់លោកអភិបាលអូលីវីយេ ផ្មឹតហាស្លេ កន្លងមកនេះ ទទួលបានសមទ្ធផលជាច្រើនស្ទើរគ្រប់វិស័យក្នុងព្រះសហគមន៍។ នេះបើតាមការបញ្ជាក់របស់គ្រីស្តបរិស័ទជាច្រើនដែលបានស្គាល់លោក។

លោកគឹម រតនា នាយកប្រតិបត្តិនៃអង្គការការីតាសកម្ពុជា និយាយថា «២៥ឆ្នាំមកនេះ ខ្ញុំឃើញថា លោកអភិបាលអូលីវីយេ បានលះបង់ចូលរួមនិងផ្តល់សេចក្តីស្រឡាញ់ដល់កម្ពុជាខ្លាំងមែនទែន ដោយយកចិត្តទុកដាក់ទាំងជំនឿ ទាំងការអភិវឌ្ឍនិងធនធានមនុស្ស»

លោករតនា បញ្ជាក់ទៀតថា លោកអភិបាលបានបង្កើតនូវវិស័យអប់រំដ៏មានគុណភាពតាំងពីថ្នាក់មត្តេយ្យរហូតដល់ឧត្តមសិក្សា ដើម្បីផ្តល់ឱកាសដល់កុមារនិងយុវជនទទួលបាននូវការសិក្សាស្មើៗគ្នា ហើយលោកបានចំណាយពេលវេលាយកចិត្តទុកដាក់កសាងព្រះសហគមន៍ រួមទាំងហេដ្ឋារចនាសម្ព័ន្ធនានាដែលមានលក្ខណៈរឹងមានខ្លាំង និងផ្តល់យោបល់ណែនាំនិងបង្កើតនូវអ្វីដែលថ្មីៗជាអត្តសញ្ញាណសម្រាប់ព្រះសហគមន៍នៅកម្ពុជាជាច្រើន។

«តាមរយៈសកម្មភាពទាំងនេះខ្ញុំសង្ឃឹមថានឹងមានអ្នកជឿលើព្រះជាម្ចាស់កាន់តែច្រើនឡើងដោយក្តីក្លាហាននិងហ៊ានចូលរួម យកចិត្តទុកដាក់លើបញ្ហាសង្គមរបស់យើងដោយប្រើជំនឿដែលយើងមាន» លោករតនាបន្ថែម។

លោកកាន់ប៊ុយ នាយកប្រតិបត្តិនៃមណ្ឌលអប់រំជំនឿសន្តអឺរ៉េណេ និយាយថា«ខ្ញុំចាប់អារម្មណ៍ទៅលើពាក្យដែលគាត់តែងតែនិយាយអំពីការប្រកាសដំណឹងល្អ ការអភិវឌ្ឍ និងការអប់រំ ហាក់បីដូចជាបានវចនាដ៏សំខាន់សម្រាប់គាត់ក្នុងការចាប់ផ្តើមបេសកកម្ម» ដោយផ្អែកលើការយកចិត្តទុកដាក់ចំពោះវិស័យអប់រំ ការថែទាំ និងបណ្តុះបណ្តាលគ្រូអប់រំជំនឿ។

ប៊ុយបន្តថា ចំពោះការអភិវឌ្ឍន៍ គាត់បានឃើញថាគ្រប់សកម្មភាពទាំងអស់ដែលគាត់ធ្វើទាំងមណ្ឌលជនពិការ យុវជន និងការអភិវឌ្ឍទាំងនៅក្នុងភូមិ ទាំងអង្គការមនុស្សធម៌ និងទំនាក់ទំនងអន្តរសាសនា ដែលគាត់យកចិត្តទុកដាក់អភិវឌ្ឍន៍ក្នុងគំនិតឈ្លាសវៃដ៏អស្ចារ្យ។ ហើយការអស្ចារ្យទាំងអស់នេះមកពីព្រះអំណោយទានរបស់ព្រះជាម្ចាស់បំភ្លឺគាត់។




លោកអូលីវីយេ ផ្មឹតហាស្លេ បានមកដល់ប្រទេសកម្ពុជាកាលពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៩៨ក្នុងនាមជាបូជាចារ្យកាតូលិក។ លោកបានចាប់ផ្តើមសកម្មភាពដំបូងនៅតំបន់កំពតនិងតាកែវ ក្នុងឆ្នាំ២០០១ ស្ថិតក្នុងភូមិភាគភ្នំពេញ។ បេសកជនរូបនេះ បានប្រាប់ថា កុំគិតថាយើងជ្រើសរើសផ្លូវរបស់យើង គឺព្រះជាម្ចាស់ដែលជ្រើសរើសឲ្យ និងព្រះជាម្ចាស់ការពារថែរក្សានៅក្នុងព្រះហឫទ័យប្រណីសន្តោស។

នៅក្នុងព្រះសហគមន៍ចំការទៀង លោកបូជាចារ្យអូលីវីយេ បានខិតខំបង្កើតព្រះសហគមន៍ដែលមានគ្រីស្តបរិស័ទម្នាក់ និងមានកម្មវិធីអប់រំជាច្រើនសម្រាប់កុមារតូចរហូតដល់យុវជនដើម្បីផ្សាយដំណឹងល្អដល់ប្រជាជនក្នុងភូមិតូចមួយនេះ។

រយៈពេលជាង២០ឆ្នាំ ព្រះសហគមន៍នេះបានសាបព្រោះដំណឹងល្អដល់តំបន់ផ្សេងៗទៀត ហើយបានបង្កើតព្រះសហគមន៍៧បន្ថែមទៀត គឺមានបាទី ត្រពាំងក្រញូង គិរីវង់ ព្រៃកប្បាស សន្តប៉ូល កំពង់អំពិល និងក្រុងតាកែវ។

លោក កុល ជាង ជាគ្រីស្តបរិស័ទដំបូងនៅព្រះសហគមន៍ចំការទៀង និងជាប្រធានព្រះសហគមន៍នេះ ដែលបានស្គាល់លោកអភិបាលអូលីវីយេ ជាង២០ឆ្នាំមកហើយឲ្យដឹងថា លោកអភិបាលអូលីវីយេតែងតែបង្ហាញផ្លូវដើម្បីប្រកាសដំណឹងល្អ ដោយរិះគិតក្នុងជួរគណៈកម្មការធ្វើយ៉ាងណាសហការរួបរួមគ្នាកសាងសេចក្តីស្រឡាញ់ កសាងព្រះសហគមន៍ឱ្យមានភាពរីកចម្រើនទៅថ្ងៃមុខ។

គណៈកម្មការរូបនេះបន្តថា លើសពីនេះទៀតលោកគង្វាលរូបនេះតែងយកចិត្តទុកដាក់ជាមួយព្រះសង្ឃនិងបងប្អូនគ្រប់សាសនា គឺជាគំរូសម្រាប់គាត់ផ្ទាល់។

បច្ចុប្បន្ននេះ ព្រះសហគមន៍មណ្ឌលសកម្មភាពតាកែវ មានកម្មវិធីជាច្រើនដូចជា កម្មវិធីអប់រំជំនឿ កម្មវិធីអប់រំកុមារនិងយុវជនកាយឫទ្ធិ កម្មវិធីសិក្សាពីកម្រិតមត្តេយ្យសិក្សាដល់ឧត្តមសិក្សា កម្មវិធីអប់រំនិងសម្តែងសិល្បៈ កម្មវិធីអភិវឌ្ឍជនបទ គម្រោងសិប្បកម្មតម្បាញសូត្រដោយក្រុមស្ត្រី ភូមិសម្រាប់កុមារមានពិការភាព កម្មវិធីអេកូទេសចរនៅភ្នំវល្លិ៍ ជាដើម។

អ្នកស្រី ខា លីន និងក្រុមគ្រួសារត្រូវបានលោកអភិបាលជួយគាំទ្រទាំងថវិកា ស្មារតី សុខភាព និងការសិក្សារបស់កូនៗ តាំងពីឆ្នាំ២០០១ ដោយសារពួកគាត់មានផ្ទុកមេរោគអេដស៍ ហើយបានទទួលជ្រមុជទឹកក្នុងឆ្នាំ២០១៥ ដោយសារសកម្មភាពមនុស្សធម៌ដែលគាត់បានទទួលនិងមើលឃើញ។

សព្វថ្ងៃអ្នកស្រីនិងគ្រួសាររស់នៅក្នុងតំបន់ព្រះសហគមន៍ចំការទៀងក្នុងខេត្តតាកែវ។ អ្នកស្រីលីនរៀបរាប់ទាំងទឹកភ្នែកទៀតថា «សេចក្តីស្រឡាញ់របស់លោកអភិបាលខ្ញុំគ្មានមធ្យោបាយអ្វីតបស្នងក្រៅពីជួយរៀបចំផ្កានៅក្នុងព្រះវិហារនិងចូលរួមគ្រប់សកម្មភាពរបស់ព្រះសហគមន៍ ដោយមិនត្រូវការប្រាក់ខែអីទេ»

មានប្រសាសន៍កាលពីថ្ងៃទី២៥ ខែមិថុនា លោកអភិបាលអូលីវីយេ ឲ្យដឹងថា ខួប២៥ឆ្នាំថ្ងៃនេះ ជាពេលវេលាដែលត្រូវអរព្រះគុណព្រះជាម្ចាស់ដែលបានថែរក្សាព្រះហសគមន៍និងរូបលោក និងរបៀបដែលព្រះអង្គបានបំភ្លឺផ្លូវជីវិត ដើម្បីឲ្យយើងរួមគ្នាសាបព្រោះជាមួយគ្រីស្តបរិស័ទពីដើមរហូតដល់សព្វថ្ងៃ។

លោកអភិបាលបន្ថែមថា ទាំងអស់នេះ ជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់ដែលធ្វើឡើងតាមរយៈមនុស្សយើងដែលជាជនតូចតាច។

លោកបញ្ជាក់ថា «ជាឱកាសមួយដែលព្រះជាម្ចាស់ប្រើយើងជាឧបករណ៍របស់ព្រះអង្គ ដើម្បីចែករំលែកជីវិតដែលព្រះជាម្ចាស់ប្រទានឲ្យ»

លោកអភិបាលអូលីវីយេ ផ្មឹតហាស្លេ ប្រសូតនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៧០ បានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យកាតូលិក នៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ១៩៩៨ ក្នុងក្រុមគ្រួសារសាសនទូតក្រៅប្រទេសក្រុងប៉ារីស នៅប្រទេសបារាំង។ លោកបានមកដល់ប្រទេសកម្ពុជានៅចុងឆ្នាំ១៩៩៨ ។ ហើយបានទទួលការតែងតាំងជាអភិបាលនាថ្ងៃទី២០ ខែមីនា ឆ្នាំ២០១០ ។

ក្នុងឱកាសខួប២៥ឆ្នាំនេះ លោកអភិបាលអូលីវីយេ ស្រមៃថាលោកនឹងមានជីវិតសាមញ្ញធម្មតាដើម្បីរស់នៅនិងបម្រើគ្រីស្តបរិស័ទឯទៀតៗ និងដើម្បីបន្តណែនាំអ្នកជំនាន់ក្រោយជាខ្មែរឲ្យបន្តធ្វើជាតំណាងនៃសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ ដោយ ធ្វើដំណើររួមគ្នានៅក្នុងផ្លូវថ្មីនៃជីវិតជាពិសេសទូលអង្វរព្រះបិតាសូមប្រទានគង្វាលដ៏សប្បុរសសម្រាប់ព្រះសហគមន៍លើទឹកដីកម្ពុជា៕

# គ្រូអប់រំជំនឿតំបន់ភ្នំពេញឈ្វេងយល់ពីធម៌ប្រកាសជំនឿ

*អត្ថបទ៖ ចាន់ ម៉ានុត*

ការិយាល័យអប់រំជំនឿបានរៀបចំកម្មវិធីសិក្ខាសាលាសម្រាប់គ្រូអប់រំជំនឿនៃ៤មណ្ឌលសកម្មភាពក្នុងតំបន់ភ្នំពេញ ក្រោមប្រធានបទ«កំណើតធម៌ប្រកាសជំនឿ»ធ្វើឡើងនៅព្រះសហគមន៍សន្តយ៉ូសែបផ្សារតូច ណែនាំដោយ លោកឧបដ្ឋាក វី សំណាង លោក ដួង សារង់ និងលោកបូជាចារ្យ ប៉ូល រឿងឆ័ត្រសិរី នាថ្ងៃទី០៨ខែកក្កដាឆ្នាំ២០២៣ដែលមានសិក្ខាកាមចូលរួមប្រមាណជា៦៥នាក់។

លោក ដួង សារង់ ប្រធានការិយាល័យអប់រំជំនឿភូមិភាគភ្នំពេញមានប្រសាសន៍ថា សិក្ខាសាលាគ្រូអប់រំជំនឿនេះ ធ្វើឡើងក្នុងគោលបំណងឱ្យគ្រូអប់រំជំនឿនៃមណ្ឌលសកម្មភាពទាំង៤យល់ដឹងថែមទៀតអំពីធម៌ប្រកាសជំនឿនិងចាប់អារម្មណ៍អំពីជំនឿរបស់ខ្លួន។

ក្នុងសិក្ខាសាលានេះ លោកសារង់បានប្រគល់ឯកសារមួយចំនួនដល់គ្រូអប់រំជំនឿ ដើម្បីឲ្យពួកគាត់រំឭកនិងរិះគិត ដើម្បីឲ្យព្រះវិញ្ញាណបំភ្លឺគាត់យល់ពីអត្ថន័យនៃធម៌ប្រកាសជំនឿហើយដោយសារកម្លាំងនៃព្រះវិញ្ញាណយើងសង្ឃឹមព្រះវិញ្ញាណនឹងធ្វើការជាមួយមនុស្សទាំងអស់ឱ្យគេចូលមកទទួលការសង្គ្រោះពីព្រះអង្គ។

សិក្ខាសាលានេះ ជាកម្មវិធីលើកដំបូងសម្រាប់គ្រូអប់រំជំនឿ ដើម្បីរិះគិតអំពីព្រះជាម្ចាស់ដែលជាព្រះបិតា។

លោកបូជាចារ្យ ប៉ូល រឿងឆ័ត្រសិរី ជាអ្នកគ្រប់គ្រងមណ្ឌលសកម្មភាពភ្នំពេញខាងជើង បានមានប្រសាសន៍ថា ធម៌ប្រកាសជំនឿ ជាធម៌អត្តសញ្ញាណគ្រីស្តបរិស័ទ ហើយធម៌នេះជួយឱ្យយើងយល់ឬបញ្ជាក់ថែម អំពីអ្វីដែលយើងជឿទៅលើព្រះជាម្ចាស់។

លោកឧបដ្ឋាកវី សំណាង ឲ្យដឹងថា ប្រសិនបើគ្រីស្តបរិស័ទមិនស្គាល់ មិនចេះ ឬមិនចាំធម៌ប្រកាសជំនឿ និងគ្មានពេលរិះគិតអំពីធម៌ជឿនេះ គ្រីស្តបរិស័ទនោះមិនដឹងមានជំនឿលើអ្វី ហើយក៏មិនអាចបញ្ជូនបន្តជំនឿរបស់បានដែរ។

លោកឧបដ្ឋាកបានបញ្ជាក់ថា ក្នុងធម៌ប្រកាសជំនឿនេះ បញ្ជាក់អំពីជំនឿរបស់គ្រីស្តបរិស័ទតាំងពីដើមដំបូងដែលបានខិតខំពន្យល់អំពីជំនឿរបស់គេ ជំនឿលើព្រះបិតា ព្រះបុត្រានិងព្រះវិញ្ញាណដ៏វិសុទ្ធ ជាព្រះត្រៃឯក ហើយនៅក្នុងធម៌ប្រកាសជំនឿបានអះអាងយ៉ាងច្បាស់អំពីព្រះយេស៊ូជាព្រះជាម្ចាស់យ៉ាងពិតប្រាកដ។

សិក្ខាសាលានេះ បានជួយលោក វី យេងឡាយជាគ្រូអប់រំជំនឿមកពីព្រះសហគមន៍អំពៅព្រៃនៃមណ្ឌលសកម្មភាពតាខ្មៅ យល់ដឹងបន្ថែមអំពីការប្រកាសជំនឿ ដើមកំណើតនៃធម៌ប្រកាសជំនឿ។ គាត់បានប្រាប់ថា កម្មវិធីនេះ ធ្វើឱ្យគាត់មានយល់ថា គាត់អាចមានសមត្ថភាពក្នុងការបញ្ជូនបន្តជំនឿច្រើនជាងមុន។

«ក្នុងនាមខ្ញុំជាគ្រូអប់រំជំនឿមួយរូប ខ្ញុំនឹងបន្តជំនឿរបស់ខ្ញុំទៅដល់ប្អូនៗជំនាន់ក្រោយ ឱ្យគាត់មានភាពក្លាហានក្នុងព្រះសហគមន៍ ហ៊ានដើរតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយសេចក្តីស្រលាញ់នឹងចែករំលែកធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ទៅដល់អ្នកក្រីក្រ» នេះជាសម្តីរបស់កញ្ញា ភឿត សុខរីន ជាគ្រូអប់រំជំនឿមកពីព្រះសហគមន៍សន្តសិលាសន្តប៉ូល ភ្នំពេញថ្មី នៃមណ្ឌលសកម្មភាពភ្នំពេញថ្មី។

បើតាមការបញ្ជាក់របស់លោក ដួង សារង់ បានឱ្យដឹងថាសិក្ខាសាលាសម្រាប់គ្រូអប់រំជំនឿក្នុងភូមិភាគភ្នំពេញនៅសល់២មណ្ឌលសកម្មភាពទៀតគឺមានមណ្ឌលសកម្មភាពទន្លេមេគង្គនឹងមណ្ឌលសកម្មភាពបាសាក់ដែលនឹងធ្វើឡើងនាពេលខាងមុខនេះផងដែរ៕

# ព្រះសហគមន៍ភូមិភាគបាត់ដំបង រំឭកអំពីមរណសាក្សីក្នុងសម័យខ្មែរក្រហម

*អត្ថបទ៖ កែវ កញ្ញា*

ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានរៀបចំកម្មវិធីរំឭកមរណសាក្សីដែលមានលោកអភិបាលប៉ូល ទេពអ៊ុម សត្ថា អតីតអភិបាលព្រះសហគមន៍កាតូលិកបាត់ដំបងពីដើម និងលោកយ៉ូហាន បាជ្រេ ដែលត្រូវបានគេសម្លាប់ក្នុងសម័យខ្មែរក្រហម រួមនិងប្រជាជននានាដែលបានស្លាប់ក្នុងសម័យនោះ។



លោកអភិបាលអេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ជាអធិបតីក្នុងកម្មវិធីនៅថ្ងៃទី១០ ខែមិថុនា មានប្រសាសន៍ថា ក្នុងជីវិតរបស់យើងជាគ្រីស្តបរិស័ទគឺមិនធ្វើតាមចិត្តនិងអារម្មណ៍របស់ខ្លួនឡើយ គឺត្រូវធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយដាក់ខ្លួនបម្រើព្រះជាម្ចាស់ ដើម្បីប្រយោជន៍រួម ប្រយោជន៍ព្រះសហគមន៍ និងប្រយោជន៍របស់ព្រះជាម្ចាស់។

លោកអភិបាបញ្ជាក់ថា កត្តាទាំងនេះ គឺដើម្បីបានជីវិតអស់កល្បជានិច្ចរួមជាមួយព្រះយេស៊ូ និងឲ្យទទួលបានផលផ្លែច្រើន។

លោកអភិបាលបន្ថែមថា មរណសាក្សីដែលយើងមាន ជាអំណោយទានរបស់ព្រះជាម្ចាស់សម្រាប់ពួកយើង។ ការលំបាកគឺជាឱកាសដែលយើងអាចជិតស្និទ្ធនឹងព្រះអង្គ ដូច្នេះយើងត្រូវអរព្រះគុណព្រះជាម្ចាស់ដែលយើងមានមរណសាក្សី ហើយបន្តឲ្យមានគ្រីស្តបរិស័ទពីមួយជំនាន់ទៅមួយជំនាន់។

លោកអភិបាលបន្តលើកទឹកចិត្តដល់គ្រីស្តបរិស័ទ ឲ្យអធិដ្ឋានអង្វរព្រះជាម្ចាស់ សូមឲ្យពួកគាត់ហ៊ាននិងទទួលឫទ្ធានុភាពពីព្រះជាម្ចាស់ដើម្បីធ្វើជាមរណសាក្សីអំពីជំនឿក្នុងជីវិតផ្ទាល់ខ្លួន។

កញ្ញា សួន សោរី ជាគ្រីស្តបរិស័ទពីស្វាយស៊ីសុផុន បានឲ្យដឹងថា ពេលគាត់ចូលរួមក្នុងកម្មវិធីរំឭកអំពីជីវិតរបស់លោកអតីតអភិបាលនាំឲ្យគាត់នឹកឃើញដល់ព្រះយេស៊ូដែលបានបូជាព្រះជន្មសម្រាប់មនុស្សទាំងអស់។

សោរី បន្តថា លោកអភិបាលទេពអ៊ុមក៏យកគំរូតាមព្រះអង្គដែរ ដោយសុខចិត្តរស់នៅក្នុងប្រទេសកម្ពុជា ទោះបីជាលោកដឹងថានឹងគ្មានជីវិតក៏ដោយ។

«ដីមរណសាក្សីនេះបានជួយខ្ញុំច្រើន នៅពេលខ្ញុំទន់ខ្សោយ ខ្ញុំស្ទើរតែបាត់បង់ជំនឿ ប៉ុន្តែនៅពេលនឹកឃើញដល់ព្រះជាម្ចាស់ធ្វើឲ្យខ្ញុំមានជំនឿឡើងវិញ និងមានសង្ឃឹម» សោរី បន្ថែម។

សុខ ហេង វ័យ៣៥ឆ្នាំមកពីប៉ោយប៉ែត និយាយថា គំរូរបស់លោកអភិបាលទេពអ៊ុម និងលោកប៉ាត្រេ បានបញ្ជាក់ថាទោះក្នុងកិច្ចការលំបាកណាក៏ដោយ ព្រះជាម្ចាស់គង់នៅជាមួយយើង និងដោយសារជំនឿ យើងនឹងមានជីវិតរួមជាមួយព្រះជាម្ចាស់។

តាមរយៈលោកទាំងពីរ បានធ្វើឲ្យហេងចេះលះបង់ពេលវេលាសម្រាប់អ្នកដទៃ លះបង់ប្រយោជន៍ផ្ទាល់ខ្លួនដើម្បីចូលរួមជួយព្រះសហគមន៍ ឲ្យយើងហ៊ាននិងតស៊ូដើម្បីជំនឿជាគ្រីស្តបរិស័ទ។

កន្លែងគោរពមរណសាក្សីក្នុងភូមិភាគបាត់ដំបងសព្វថ្ងៃ គឺព្រះសហគមន៍ភូមិភាគបាត់ដំបង បានស្នើសុំដីមួយកន្លែងពីរដ្ឋាភិបាលក្បែរស្ពានបត់ត្រង់ ដែលគេដឹងថា ជាកន្លែងអស់លោកត្រូវបានគេសម្លាប់ ទុកជាទី រំឭកជារៀងរាល់ឆ្នាំ។

លោកប៉ូល ទេព អ៊ុម សុត្ថា កើតនៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៣៤ នៅក្រុង ភ្នំពេញ លោកជាកូនកាត់ខ្មែរ-បារាំង-វៀតណាម។ នៅឆ្នាំ១៩៤៧ លោកបានទៅ រស់នៅប្រទេសបារាំង។ លោកបានស្តាប់ឮការត្រាស់ហៅរបស់ព្រះជាម្ចាស់តាមរយៈ សកម្មភាពកុមារកាយរិទ្ធនៅទីនោះ បន្ទាប់មកលោកបានចូលរៀនទេវវិទ្យាល័យ និងបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៥៩ នៅវិសាលវិហារព្រះនាងម៉ារី នៅទីក្រុង ប៉ារីសប្រទេសបារាំង។ លោកបានបន្តការសិក្សានៅទីក្រុងរ៉ូម។

នៅឆ្នាំ១៩៦១ លោកត្រឡប់មកប្រទេសកម្ពុជាវិញ។ លោកខិតខំបង្កើតទំនាក់ទំនងជាមួយបងប្អូនខ្មែរ ឡើងវិញ ក្រោយអវត្តមាននៅប្រទេសកម្ពុជាអស់រយៈពេលដ៏យូរ។ លោកបានជួយក្រុមជាច្រើនរិះគិត អំពីជំនឿ សង្គម និងវប្បធម៌។

លោកទទួលការតែងតាំងជាអភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបងនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៦៨ ក្នុងជន្មាយុ៣៥ឆ្នាំ។ ក្នុងអភិបូជា នាថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៥ លោកអភិបាល ទេព អ៊ុម ធ្វើពិធីលើកលែងទោសទូទៅ ហើយប្រទានពរដល់គ្រីស្តបរិស័ទទាំងអស់ថា៖ «ថ្ងៃនេះ ជាថ្ងៃចុងក្រោយបង្អស់ ដែលខ្ញុំប្រសិទ្ធិពរ បងប្អូនរាល់គ្នា... ខ្ញុំសូមលើកលែងទោសរំដោះបាបអស់បងប្អូនដែលនៅក្នុងវិហារ និងបងប្អូនដែលពុំបានមកផង»៕

# បាល់ទាត់មិត្តភាពពានរង្វាន់លោកអភិបាលអេនរីគេ ហ្វីការេដូ

*កែវ កញ្ញា*

សំឡេងហ៊ោកញ្ជៀវនៅតារាងបាល់ទាត់របស់អ្នកទស្សនាក្នុងព្រះសហគមន៍កាតូលិកពេទ្យយាយជីនាក្រុងបាត់ដំបងចំពោះជ័យជំនះនៃក្រុមកីឡាករដែលពួកគាត់បានរង់ចាំមើលជិត២ខែមក ហើយនោះបានចេញជាលទ្ធផលហើយ កាលពីពេលថ្មីកន្លងទៅ។









យុវជន យុវនារីពីព្រះសហគមន៍នានាក្នុងភូមិភាគបាត់ដំបង បានរៀបចំជាក្រុមៗដើម្បីប្រកួតបាល់ទាត់មិត្តភាពពានរង្វាន់លោកអភិបាលអេនរីគេ ហ្វីការេដូ ដែលបានចាប់ផ្តើមកាលពីថ្ងៃទី២០ ខែឧសភាកន្លងទៅ ហើយបានបិទបញ្ចប់នៅថ្ងៃទី៣ខែកក្កដានេះ។

វុធពិសី អាយុ២៣ឆ្នាំ តំណាងក្រុមបាត់ទាត់បុរសនៃសាលាដុនបូស្កូបាត់ដំបង និយាយថា កម្មវិធីនេះជួយ«ឲ្យយើងស្គាល់គ្នា និងចៀសឆ្ងាយពីគ្រឿងញៀននិងដើរតាមគន្លងរបស់ព្រះអង្គ (ព្រះយេស៊ូ)។»

ត្រា លីតា អាយុ១៩ឆ្នាំ ក្រុមបាល់ទាត់ស្ត្រីមកពីព្រះសហគមន៍តាហែន បាននិយាយថា ថ្ងៃនេះនាងមានអារម្មណ៍សប្បាយចិត្តពេលដែលក្រុមរបស់ខ្លួននិងក្រុមមិត្តភក្តិទទួលបានជ័យលាភី។

លីតាបានឲ្យដឹងទៀតថា កម្មវិធីប្រកួតបាល់ទាត់ពានលោកអភិបាល បានជួយដល់ទំនាក់ទំនងក្នុងព្រះសហគមន៍រវាងយុវជននិងយុវជន។ «យើងមានការស្និទ្ធស្នាលគ្នាពេលលេងជាមួយគ្នា ស្គាល់គ្នាកាន់តែច្បាស់ ស្គាល់ពីអត្តចរិក សុជីវធម៌របស់មនុស្សម្នាក់ៗ។»

កីឡាករិនីក្នុងក្រុមជាប់ពានលេខ១ផ្នែកបាល់ទាត់នារីរូបនេះ សូមអរគុណដល់លោកអភិបាលអេនរីគេ ហ្វីការេដូ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងដែលបានបង្កើតកម្មវិធីនេះឡើងដើម្បីឲ្យពួកគាត់បានស្គាល់គ្នានិងអបអរសាទរខួបតែងតាំងលោកជាអភិបាលព្រះសហគមន៍។

កម្មវិធីប្រកួតបាល់ទាត់ដែលមានរយៈពេល៧សប្តាហ៍នេះ បានរៀបចំការប្រកួតជារៀងរាល់សប្តាហ៍គឺថ្ងៃសៅរ៍និងថ្ងៃអាទិត្យ ដែលចូលរួមពីសំណាក់យុវជនគ្រីស្តបរិស័ទតាមព្រះសហគមន៍និងស្ថាប័ននានា ដែលមានក្រុមប្រកួតបុរសចំនួន១៦ក្រុម ក្រុមស្ត្រី ៨ក្រុម។

លោកអភិបាលអេនរីគេហ្វីការេដូមានប្រសាសន៍ថា កម្មវិធីនេះ គឺធ្វើឡើងដើម្បីនាំអំណរសប្បាយដល់យុវជន និងទុកពេលឲ្យពួកគាត់ស្គាល់គ្នាកាន់តែច្រើនតាមរយៈកីឡា និងដើម្បីឲ្យព្រះសហគមន៍នៅក្នុងតំបន់ មានភាពអ៊ូរអរផង។

ជ័យលាភីលេខ១ផ្នែកបុរសបានទៅក្រុមសាលាដុនបូស្កូបាត់ដំបង រីឯផ្នែកស្ត្រីបានទៅលើក្រុមព្រះសហគមន៍តាហែន៕

# ព្រះសហគមន៍ខ្នាចរមាសនឹងមានព្រះវិហារថ្មីឆាប់ៗ

*អត្ថបទ៖ ចាន់ ម៉ានុត*

ព្រះវិហារធម៌មេត្តាករុណាព្រះជាម្ចាស់ខ្នាចរមាស ស្ថិតនៅភូមិកោះរាម ឃុំខ្នាចរមាស ស្រុកបវេល ខេត្តបាត់ដំបង នឹងមានព្រះវិហារថ្មីឆាប់ៗនេះ។ នេះបើតាមការបញ្ជាក់របស់លោក ម៉ានុច កុមារឯកា ជាបូជាចារ្យទទួលខុសត្រូវ។

នាព្រឹកថ្ងៃទី០៩ខែមិថុនាកន្លងទៅ លោកអភិបាល អេនរីគេ ហ្វីការេដូ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានធ្វើជាអធីបតីក្នុងពិធីបញ្ចុះបឋមសិលា សម្រាប់សាងសង់ព្រះវិហារថ្មី ដោយរួមជាមួយលោកបូជាចារ្យ ដូនជី និងគ្រីស្តបរិស័ទប្រមាណជា១០០នាក់។



អ្នកស្រីឡា សុខា វ័យ៥២ឆ្នាំ ជាគ្រីស្តបរិស័ទនៅព្រះសហគមន៍នេះ ឲ្យដឹងថា នៅរដូវវស្សារាល់ពេលដែលថ្វាយអភិបូជាគឺតម្រូវឱ្យបងប្អូនគ្រីស្តបរិស័ទលើកអាសនៈទៅក្រោមផ្ទះធំដើម្បីថ្វាយបង្គំព្រះជាម្ចាស់ ហើយពេលមានពិធីបុណ្យធំៗក៏មានការលំបាកដែរ ដោយសារព្រះវិហារតូចចង្អៀត។

អ្នកស្រីបន្ថែមថា «នៅពេលដឹងថាមានព្រះវិហារថ្មីគឺសប្បាយចិត្តខ្លាំងព្រោះយើងលែងចង្អៀត លែងលិចទឹកនិងមិនពិបាកសែងអាសនៈចុះឡើងទៀតហើយ»

លោកបូជាចារ្យ ម៉ានុច កុមារឯកា មានប្រសាសន៍ថា ដោយសារកត្តានេះ លោកបានខិតខំស្វែងរកជំនួយទាំងក្នុងនិងក្រៅប្រទេស ដើម្បីសាងសង់ព្រះវិហារថ្មីសម្រាប់ថ្វាយបង្គំព្រះជាម្ចាស់។





លោកថា ៖ «នៅពេលមានព្រះវិហារស្អាតណែនាំឱ្យយើងមានអារម្មណ៍ល្អព្រោះព្រះវិហារជាកន្លែងទំនាក់ទំនងជាមួយព្រះជាម្ចាស់ សន្ទនាជាមួយព្រះជាម្ចាស់នឹងជាពិសេសការអធិដ្ឋានគឺត្រូវស្ងប់ចិត្ត»។

នៅក្នុងកម្មវិធីចុះបឋមសិលានាថ្ងៃនោះដែរ អ្នកចូលរួមទាំងអស់បានដង្ហែជុំវិញបរិវេណគម្រោងសាងសង់ព្រះវិហារថ្មីចំនួន៣ជុំដោយមានពន្លឺទៀនព្រះជ័យនាំមុខព្រះឈើឆ្កាងលាយឡំជាមួយនិងចម្រៀងយ៉ាងពីរោះរណ្តំ។

ក្នុងពិធីនោះ ក៏មានពិធីបាចអំបិល និងអុជទៀនក្នុងបរិវេណដីសាងសង់ ដែលជានិមិត្តរូបរំឭកគ្រីស្តបរិស័ទអំពីតួនាទីនិងកាតព្វកិច្ចរបស់ខ្លួន។

លោកបូជាចារ្យ ទម្លាប់ សុផល ជាអតីតបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍នេះ បានពន្យល់ថា គ្រីស្តបរិស័ទត្រូវធ្វើជាអំបិលមានជាតិប្រៃ គឺត្រូវរស់នៅនិងអនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយធ្វើជាពន្លឺរបស់ព្រះជាម្ចាស់ ដើម្បីនាំមនុស្សឯទៀតៗស្គាល់ព្រះជាម្ចាស់។





ក្នុងពិធីនោះដែរ លោកអភិបាលអេនរីគេ មានប្រសាសន៍ថា ពេលនេះជាពេលវេលាដែលយើងត្រូវអរព្រះគុណព្រះជាម្ចាស់សម្រាប់ព្រះវិហារថ្មី។

លោកអភិបាលបញ្ជាក់ថា ព្រះជាម្ចាស់មិនត្រូវការព្រះវិហារទេ គឺព្រះអង្គត្រូវការយើង តែយើងទេដែលត្រូវការព្រះវិហារដើម្បីនៅជិតស្និទ្ធជាមួយព្រះអង្គ និងជួបជុំគ្នាដើម្បីប្រកាសធម៌មេត្តាករុណារបស់ព្រះអង្គ។

លោកអភិបាលបានលើកទឹកចិត្តដល់គ្រីស្តបរិស័ទនៅទីនេះថា ព្រះវិហារថ្មីនេះជាសញ្ញាសម្គាល់ថាយើងចេះរួបរួមគ្នា យើងកសាងព្រះសហគមន៍រួមគ្នា យើងចេះសម្រុះសម្រួលគ្នា យើងចេះលើកទឹកចិត្តគ្នាដូចក្រុមសាវ័ករួបរួមគ្នាជាមួយព្រះយេស៊ូទោះបីជាមានឧបសគ្គច្រើនប៉ុន្តែយើងសុខចិត្តលះបង់នឹងដើរតាមព្រះអង្គ។

«ទោះបីជាយើងមានជាមនុស្សល្អឬមិនល្អ ព្រះជាម្ចាស់មានចិត្តមេត្តាករុណា ចិត្តស្រលាញ់ និងចង់ឱ្យយើងចេះកែប្រែ ហើយព្រះអង្គគង់នៅជាមួយយើងរហូត»។ លោកអភិបាលបញ្ជាក់ថា ៖ «ដូច្នេះយើងត្រូវមានអំណរសប្បាយក្នុងដួងចិត្ត»។

ក្រោយបញ្ចប់ធម្មទេសនាលោកអភិបាលបានទ្រាបដៃលើរណ្តៅដោយអធិដ្ឋាន បន្ទាប់មកលោកដាក់ដីមរណសាក្សី រូបឈើឆ្កាង ធម៌ប្រកាសជំនឿ ធម៌ឱព្រះបិតា និងបញ្ជីឈ្មោះគ្រីស្តបរិស័ទចូលក្នុងបំពង់មួយ ហើយកប់ទៅក្នុងដីដែលនឹងក្លាយជាកន្លែងរៀបចំតុអាសនៈ។

តាមការឲ្យដឹងរបស់លោកបូជាចារ្យម៉ានុច ប្រាប់ថា សំណង់នឹងរួចរាល់ក្នុងពេលពី៦ទៅ៨ខែទៀត។ ព្រះវិហារថ្មីមានទំហំទទឹង១០ម៉ែត្រនិងបណ្តោយ៣០ម៉ែត្រ ហើយអាចទទួលមនុស្សបានពី៣០០ទៅ៤០០នាក់។

លោកបន្ថែមទៀតថា ព្រះវិហារនេះ ចំណាយប្រាក់ជិត១០ម៉ឺនដុល្លារអាមេរិក ហើយថវិកាពាក់កណ្តាលបានមកពីសប្បុរជនក្រៅប្រទេស និងមួយចំនួនទៀតកំពុងស្វែងរកបន្ថែម។

លោកថា ជាមួយគ្នានេះដែរ ក៏មានគ្រីស្តបរិស័ទក្នុងប្រទេសមួយចំនួនបានឧបត្ថម្ភជាសម្ភារផ្សេងៗសម្រាប់ដាក់ក្នុងព្រះវិហារផងដែរ។

ព្រះវិហារធម៌មេត្តាករុណាព្រះជាម្ចាស់ស្ថិតនៅក្នុងភូមិភាគបាត់ដំបង ជាព្រះសហគមន៍ដែលបែកចេញពីព្រះសហគមន៍ចំណោម។ ព្រះសហគមន៍នេះបានកកើតឡើងវិញនៅឆ្នាំ១៩៩៩ ដែលសព្វថ្ងៃមានគ្រីស្តបរិស័ទប្រមាណចំនួន៦៥នាក់ និងមាន១៥នាក់ដែលកំពុង ឈ្វេងយល់អំពីជំនឿ៕

# ដំណឹងល្អបានឮដល់ជនជាតិដើមភាគតិចនៅខេត្តរតនគិរី







*អត្ថបទ៖ កែវ កញ្ញា*

រតនគិរីជាខេត្តមួយនៅភាគឥសាន្តនៃប្រទេសកម្ពុជា មានចំងាយប្រមាណជិត៥០០គីឡូម៉ែត្រពីរាជធានីភ្នំពេញ និងមានជនជាតិដើមភាគតិច រស់នៅប្រមាណ៦០%នៃប្រជាជនសរុប ដូចជាជនជាតិទំពួន កាចក់ ការ៉ែត លន់ ព្រៅ ចារាយ ព្នង និង គ្រឹង ជាដើម។

ព្រះសហគមន៍កាតូលិកបានកកើតក្នុងតំបន់នេះ ក្នុងអំឡុងឆ្នាំ១៩៩២ គឺក្រោយពេលប្រទេសកម្ពុជាទទួលបានសន្តិភាព។

លោកអ៊ីវ៉ាន់ កាំប៉ាញ៉ាស្វារេស ជាបូជាចារ្យទទួលខុសត្រូវតំបន់នេះមានប្រសាសន៍ថា ក្នុងចំណោមប្រជាជន សរុបជាង២០ម៉ឺននាក់ គ្រីស្តបរិស័ទកាតូលិកមានត្រឹមតែ៥០នាក់ប៉ុណ្ណោះ។

ក្នុងឆ្នាំ២០១៨ លោកអ៊ីវ៉ាន់ កាំប៉ាញ៉ាស្វារេស ជាសាសនទូតក្រុមយ៉ារ៉ូម៉ាល់ មកពីប្រទេសអេក្វាឌ័រ ត្រូវបានចាត់ដោយលោកអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាមឲ្យមកប្រកាសដំណឹងល្អដោយរស់នៅទីនេះជាមួយបូជាចារ្យផ្សេងទៀត នៅក្រុងបានលុងជាទីរួមខេត្តរតនគិរី។

លោកអ៊ីវ៉ាន់ កាំប៉ាញ៉ា ស្វារេស ជាបូជាចារ្យទទួលខុសត្រូវនៅតំបន់នេះ បានរៀបរាប់អំពីក្នុងអំឡុងពេល៣-៤ឆ្នាំដំបូងដែលលោកបានមករស់នៅទីនេះជាមួយក្រុមដូនជីយ៉ាងនេះថា «យើងព្យាយាមផ្សព្វផ្សាយបង្ហាញមេត្តាករុណា សេចក្តីស្រឡាញ់ទៅកាន់អ្នកភូមិ អ្នករស់នៅជាមួយយើង ប៉ុន្តែគ្មាននរណារវីរវល់នឹងសាសនាទេ»។

លោកបន្ថែមថា នេះនាំឲ្យយើងគិតថា ប្រហែលយើងរស់នៅជិតផ្សារពេក ជាកន្លែងរកស៊ីនិងធ្វើការប្រហែលបងប្អូននៅក្នុងកន្លែងនេះ គេមិនសូវរវីរវល់នឹងសាសនាប៉ុន្មានទេ ហើយគេមានសាសនាច្បាស់លាស់ និងគេមិនចង់ដូរទេ។ យើងព្យាយាមធ្វើរបៀបផ្សេងៗឲ្យគេចាប់អារម្មណ៍តែអត់មានន័យទេ។

ដោយសារកត្តានេះ លោកបានសម្រេចចិត្ត ទៅតាមភូមិឬជនបទ ដើម្បីឲ្យផ្សាយដំណឹងល្អពីព្រះយេស៊ូ ជាពិសេសគឺទៅដល់ជនជាតិដើមភាគតិចមួយចំនួនដែលក្រីក្រ និងត្រូវការផ្លូវជីវិតមួយពិតប្រាកដ។

លោកបានរៀនភាសាទំពួនដែលជាភាសាជនជាតិដើមដែលមានស្ថិតិរស់នៅច្រើនជាងគេក្នុងតំបន់។ លោកបានឲ្យដឹងថា នៅទីនេះ ការរស់នៅរបស់ជនជាតិភាគតិចគឺខុសគ្នា ហើយមានសាសនាផ្សេង «គឺអារក្សអ្នកតា»។

«សម្រាប់ខ្ញុំការប្រកាសដំណឹងល្អនៅតំបន់នេះ ជាបទពិសោធន៍ថ្មី ដែលឲ្យខ្ញុំពេលខ្លះរិះគិតពិចារណាថា យើងធ្វើយ៉ាងម៉េច ដើម្បីឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់បានទៅដល់ជីវិតរបស់ពួកគាត់ ហើយមិនប៉ះពាល់ដល់របៀបរស់នៅរបស់ពួកគាត់។» លោកអ៊ីវ៉ាន់បន្ថែម។

គណៈកម្មការព្រះសហគមន៍រតនគិរីដែលមានលោកបូជាចារ្យនិងដូនជី បានរៀបចំជាជំហានៗ ដើម្បីឲ្យព្រះសហគមន៍មានជីវិតនិងមានការចូលរួមពីប្រជាជននិងគ្រីស្តបរិស័ទ ដោយថែរក្សា អប់រំ និងសួរសុខទុក្ខតាមតំបន់និងភូមិតាមតែពួកគាត់អាចធ្វើទៅបាន។

នៅព្រះវិហារសន្តយ៉ូហាន ដែលជាទីតាំងកកើតរបស់ព្រះសហគមន៍ មានគ្រីស្តបរិស័ទជួបជុំជារៀងរាល់ថ្ងៃអាទិត្យ ហើយក៏មានកម្មវិធីផ្សេងៗមួយចំនួនដើម្បីពង្រឹងជំនឿ និងឲ្យពួកគាត់ស្គាល់គ្នា។

លោកបូជាចារ្យទទួលខុសត្រូវបន្ថែមថា ការប្រមែប្រមូលគ្រីស្តបរិស័ទដែលមិនមកវិហារឲ្យមកវិញដោយមានអធិដ្ឋានតែហែរតាំងព្រះកាយព្រះគ្រីស្តហើយយើងទៅសួរសុខទុក្ខគ្រីស្តបរិស័ទតាមផ្ទះ ដើម្បីស្គាល់គ្នា និងអញ្ជើញគេត្រឡប់មកវិហារវិញ។

ដើម្បីទៅកាន់តែជ្រៅក្នុងជីវិតរបស់ប្រជាជនក្រីក្រ ដែលជាជនជាតិភាគតិចលោកបូជាចារ្យនិងដូនជីបានរិះគិតរួមគ្នាបង្កើតសកម្មភាពបន្ថែម គឺបណ្តាលសិស្សស្នាក់នៅសម្រាប់កូនៗរបស់ជនជាតិដើមភាគតិចបន្តការសិក្សានៅអនុវិទ្យាល័យនិងវិទ្យាល័យនៅក្នុងក្រុងបានលុង។

ក្នុងមណ្ឌលសិស្សនេះ មានជំទង់និងយុវជនចំនួន១០នាក់ដែលមានជនជាតិ២គឺ ទំពួន និងចារាយ ដែលពួកគាត់មិនមែន



ជាគ្រីស្តបរិស័ទ។

បា ម៉ឹម រៀនថ្នាក់ទី១០ និយាយថា ការរស់នៅក្នុងមណ្ឌល និងនៅផ្ទះខុសគ្នាឆ្ងាយណាស់ ដោយសារនៅផ្ទះមិនមានម្ហូបអាហារហូបចុកគ្រប់គ្រាន់ នៅទីនេះមានជំនួយ «ហើយការរៀនសូត្រក៏ជោគជ័យជាងនៅផ្ទះ ដោយសារនៅផ្ទះយើងអត់សូវមានពេលរៀនច្រើនដោយសារតែជួយធ្វើការផ្ទះ ទៅចម្ការ ឬស៊ីឈ្នួលគេអីចឹង ហើយនៅទីនេះអត់មានធ្វើអីទេ ក្រៅពីការសិក្សាប៉ុណ្ណោះ។»

នោ បូទ្រី រៀនថ្នាក់ទី១២ មកពីស្រុកបរកែវ ឲ្យដឹងដែរថា នៅទីនេះ គេបានផ្តល់កន្លែងស្នាក់នៅ កន្លែងរៀន ម្ហូបអាហារមានគ្រប់គ្រាន់ ហើយយើងមានពេលរៀនច្រើនជាងយើងនៅភូមិ ដោយសារនៅភូមិវាឆ្ងាយពីទីរួមខេត្តពិបាកធ្វើដំណើរទៅរៀន ហើយម្យ៉ាងទៀតនៅភូមិអត់មានសាលារៀនដល់វិទ្យាល័យដែរ។

បូទ្រី បន្ថែមថា «អនុវិទ្យាល័យគេទើបបង្កើតបាន២ឆ្នាំនៅភូមិរបស់ខ្ញុំ។ ខ្ញុំមកហ្នឹងបានរយៈពេល៥ឆ្នាំហើយ។ អនាគតចង់ធ្វើជាគ្រូបង្រៀន។»

លោកបូជាចារ្យអ៊ីវ៉ាន់ និយាយថា យុវជនទាំងនោះមកពីភូមិផ្សេងៗ ឆ្ងាយដាច់ស្រយាល និងជាអ្នកក្រីក្រ យើងមានបំណងជួយពួកគាត់ឲ្យមានឱកាសរៀនសូត្រដល់ពេលក្រោយ អាចជួយសង្គមដែរ។

«ជាទូទៅយើងឃើញថា បងប្អូនជនជាតិដើមភាគតិចឈប់រៀន មកពីសេដ្ឋកិច្ច។ ពួកគេត្រូវការទៅនៅខេត្ត ត្រូវការបន្ទប់រៀន បន្ទប់ដេក ម្ហូបអាហារអីចឹងទៅ។» លោកបន្ថែមថា ក្មេងស្រីៗអាយុ១២ឆ្នាំដល់២០ ត្រូវតែរៀបការ។ ឪពុកម្តាយ គិតថាកូនៗជាកម្លាំងដើម្បីជួយធ្វើចម្ការ «ដោយសារជីវិតរបស់ពួកគាត់មកពីចម្ការ ម្ហូបមកពីចម្ការ លុយមកពីចម្ការ អីចឹងអត់ធ្វើចម្ការទេ អត់រស់។»

លោកអ៊ីវ៉ាន់ គ្រោងនឹងបន្តរកជំនួយដើម្បីសាងសង់នូវអាគារច្រើនជាន់ដើម្បីអាចទទួលយុវជនបន្ថែមទៀតឲ្យស្នាក់នៅដើម្បីរៀនសូត្រ។ លោកថា «បច្ចុប្បន្នមានផ្ទះឈើ មានតែមួយជាន់ទេ។ ដើម្បីធ្វើអគារថ្មី យើងត្រូវការរកលុយ ដើម្បីកសាងអាគារ។» ពេលណាមានអាគារថ្មីអាចទទួល២០នាក់បាន។

រាល់ថ្ងៃអាទិត្យ មានយុវជនខ្លះ បានសុំរៀនអប់រំជំនឿ ដើម្បីស្គាល់ព្រះយេស៊ូ ដែលក្នុងនោះមានទំពួន២ និងចារ៉ាយ២។

ជាមួយបេសកកម្មនៅក្នុងខេត្តភាគឥសាន្តមួយនេះ ព្រះសហគមន៍បានទិញដីចម្ការមួយនៅមិនឆ្ងាយពីទីរួមខេត្តប៉ុន្មានទេ ដើម្បីផលិតដំណាំជួយទ្រទ្រង់ការចំណាយមួយផ្នែកផងដែរ។

ដោយសារជនជាតិដើមភាគតិចភាគច្រើនត្រូវការជំនួយទាំងស្មារតីនិងការអប់រំ ព្រះសហគមន៍បានរៀបចំទិញដីមួយកន្លែងនៅបរកែវ ដែលមានចំងាយពីទីរួមខេត្តប្រមាណ៤៥គីឡូម៉ែត្រពីក្រុងបានលុង ដើម្បីចូលឲ្យជ្រៅទៅក្នុងជីវិតនិងវប្បធម៌របស់ជនជាតិដើមភាគតិច ជាពិសេសទំពួន និងចារាយ។

នៅទីនោះព្រះសហគមន៍នឹងរៀបចំជាសាលាមត្តេយ្យសម្រាប់កូនតូចៗរបស់ជនជាតិដើមភាគតិចទំពួនដែលមានចំនួនមនុស្សរស់នៅច្រើនជាងគេក្នុងខេត្តនេះ ហើយនៅទីនោះមានចម្ការដំណាំនិងកន្លែងសំណាក់ធម៌សម្រាប់គ្រីស្តបរិស័ទជាដើម។

ទោះជាការងាររវល់យ៉ាងណា កិច្ចការថែរក្សាកូនចៀមរបស់ព្រះជាម្ចាស់ក៏នៅតែបន្តស្វែងរក។ លោកអ៊ីវ៉ាន់និងក្រុមដូនជីបានទៅដល់តំបន់ផ្សេងៗដែលគ្រីស្តបរិស័ទរស់នៅឆ្ងាយ ដូចជាវឿនសៃដែលមានចំងាយប្រមាណ៨០គីឡូពីទីរួមខេត្ត ដែលមានគ្រីស្តបរិស័ទរស់នៅទីនោះមួយគ្រួសារ។ នៅទីនោះ អស់លោកបង្រៀនអធិដ្ឋាន និងសូត្រធម៌ ព្រមទាំងអប់រំជំនឿ ដើម្បីឲ្យកូនៗរបស់គាត់អាចទទួលអគ្គសញ្ញានានាបាន៕

# លោក អេនរីគេ៖
# ២៣ឆ្នាំជាអភិបាល អំណរសប្បាយមានច្រើន

*អត្ថបទ៖ កែវ កញ្ញា*



លោកអភិបាលអេនរីគេ ហ្វីការេដូ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង មានប្រសាសន៍ថា ក្នុងរយៈពេល២៣ឆ្នាំជាអភិបាល លោកមានអំណរសប្បាយច្រើន មានឧទាហរណ៍ច្រើន មានកូនច្រើនដែលនាំឲ្យលោកមានអំណរសប្បាយដែលមកពីព្រះជាម្ចាស់។

លោកអភិបាលមានប្រសាសន៍នេះ បន្ទាប់ពីពិធីថ្វាយអភិបូជាសម្រាប់ខួបលើកទី២៣ឆ្នាំដែលសម្តេចប៉ាបបានជ្រើសតាំងលោកឲ្យក្លាយជាអ្នកទទួលខុសត្រូវលើព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង កាលពីថ្ងៃទី៣ខែកក្កដាកន្លងមក នៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ក្នុងខេត្តបាត់ដំបង។

ចាប់តាំងពីលោកបានក្លាយជាអភិបាលព្រះសហគមន៍ក្នុងភូមិភាគបាត់ដំបង ចំណុចសំខាន់ដែលនាំឲ្យលោកបន្តដំណើរទៅមុខបាន គឺគ្រីស្តបរិស័ទចេះបង្ហាញសេចក្តីស្រឡាញ់ លើកទឹកចិត្តគ្នា និងសហការគ្នា។ លោកថា «ពេលណាខ្ញុំឃើញនោះ ខ្ញុំមានអំណរសប្បាយមែនទែន ខ្ញុំមានកម្លាំងណាស់ដើម្បីទៅមុខ ហើយកម្លាំងនេះមកពីព្រះជាម្ចាស់។»

លោកអភិបាលបានប្រាប់ទៀតថា ព្រះអំណោយទានជាច្រើនដែលលោកទទួលពីព្រះជាម្ចាស់គឺបានតាមរយៈគ្រីស្តបរិស័ទទាំងអស់។

ក្នុងកិច្ចការដែលលោកបានធ្វើ គឺសំខាន់បំផុតឲ្យគ្រីស្តបរិស័ទកាន់ជំនឿរបស់ខ្លួនឲ្យមាំមួន និងត្រូវមានចិត្តមេត្តាករុណាដូចព្រះបិតាដែលគង់នៅស្ថានបរមសុខ។

«ឲ្យយើងយកជំនឿជាម្ចាស់ជីវិតយើង យកព្រះជាម្ចាស់មុនក្រុមគ្រួសារ មុនការងារ គឺឲ្យជំនឿជាគ្រឹះក្នុងជីវិតរបស់យើង» លោកអភិបាលបញ្ជាក់ «ត្រូវមានចិត្តមេត្តាករុណា ដោយមានចិត្តអាណិតអ្នកដទៃ ដោយបង្ហាញធម៌មេត្តាករុណាពីព្រះជាម្ចាស់ដល់បងប្អូន។»

លោកបន្ថែមថា បើសិនយើងចង់មានដំណាក់កាលទៅខាងមុខស្របតាមគោលការរួមរបស់សម្តេចប៉ាប គឺយើងត្រូវការជំនឿនិងសេចក្តីស្រឡាញ់ដែលនាំឲ្យយើងមានសេចក្តីសង្ឃឹមដែលអាចផ្តល់សក្ខីភាពដល់បងប្អូនឯទៀតៗ ហើយឲ្យយើងធ្វើជាមនុស្សល្អនិងប្រសើរជាងសម្រាប់អ្នកដទៃ។

ក្នុងថ្ងៃដដែលនោះ ត្រូវនឹងពិធីបុណ្យរំឭកដល់សន្តថូម៉ាសជាគ្រីស្តទូត ដែលដំណឹងល្អនិយាយអំពីស្នាមរបួសរបស់ព្រះយេស៊ូ។ ឆ្លៀតក្នុងឱកាសនោះ លោកអភិបាលអេនរីគេ មានប្រសាសន៍ក្នុងធម្មទេសនាដល់គ្រីស្តបរិស័ទដែលចូលរួម ឲ្យស្វែងរកស្នាមរបួសរបស់ព្រះយេស៊ូ ដែលប្រៀបដូចជាឧបសគ្គដែលយើងមាននៅក្នុងជីវិត។

លោកអភិបាលបញ្ជាក់ថា ស្នាមរបួសដែលយើងមាន គឺមនុស្សដែលមានពិការភាព គឺកុមារអនាថា គឺយុវជនដែលគ្មានឱកាសទទួលអប់រំ និងនៅកន្លែងដែលមានសង្គ្រាម។

លោកបន្ថែមថា «បើចង់ស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ សូមទៅរកស្នាមរបួសរបស់ព្រះអង្គ។ ស្នាមរបួសជាបញ្ហាមួយ ប៉ុន្តែព្រះជន្មដែលយើងនឹងទទួលពីព្រះយេស៊ូគឺនៅទីនោះ។»

លោកអភិបាលរំលឹកថា ព្រះយេស៊ូមានព្រះបន្ទូលឲ្យយើងដឹងថា ជីវិតពីព្រះជាម្ចាស់មានកម្លាំងច្រើនជាងឧបសគ្គ ច្រើនជាងសេចក្តីស្លាប់ និងអំពើឃោឃៅរបស់លោកិយនេះ។

ក្នុងពិធីខួបលើកទី២៣ឆ្នាំជាអភិបាលនេះ គ្រីស្តបរិស័ទពីព្រះសហគមន៍នានាបានចូលរួមយ៉ាងច្រើនកុះករ នៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ នាក្រុងបាត់ដំបង។ ពួកគាត់បានជូនផ្កានិងអំណោយមួយចំនួនជូនលោកអភិបាលអេនរីគេ ដើម្បីនឹកគុណចំពោះការលះបង់របស់លោកក្នុងកិច្ចការបម្រើនិងណែនាំព្រះសហគមន៍ក្នុងភូមិភាគបាត់ដំបង។

លោកអេនរីគេ ហ្វីការេដូ ប្រសូតនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៥៩ នៅប្រទេសអេស្ប៉ាញ ជាកូនទី៧ ក្នុងចំណោមបងប្អូនចំនួន៨នាក់។ លោកបានចូលបួសក្នុងក្រុមសហជីវិនព្រះយេស៊ូក្នុងឆ្នាំ១៩៧៩។ ក្នុងឆ្នាំ១៩៨៥ លោកស្ម័គ្រចិត្តមកបម្រើប្រជាជនកម្ពុជាក្នុងជំរំខ្មែរថៃ នៅប្រទេសថៃ។ បន្ទាប់មកលោកធ្វើការនៅក្នុងប្រទេសកម្ពុជា ហើយវិលត្រឡប់ទៅប្រទេសកំណើតវិញដើម្បីតែងតាំងជាបូជាចារ្យក្នុងឆ្នាំ១៩៩២។

ក្នុងឆ្នាំ១៩៩១ លោកចូលរួមបង្កើតនិងទទួលខុសត្រូវមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបន្ទាយព្រាប ដើម្បីជួយគាំទ្រនិងផ្តល់ការសិក្សាអប់រំដល់ជនមានពិការភាពដោយសារមីន។

លោកអេនរីគេ ហ្វីការេដូ ត្រូវបានសម្តេចប៉ាបយ៉ូហានប៉ូលទី២ ជ្រើសតាំងទទួលមុខងារណែនាំព្រះសហគមន៍កាតូលិកក្នុងភូមិភាគបាត់ដំបង កាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០០។

ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង គ្របដណ្តប់លើខេត្តចំនួន៩ ក្នុងនោះរួមមាន បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ធំ សៀមរាប ព្រះវិហារ ឧត្តរមានជ័យ ប៉ៃលិន និងបន្ទាយមានជ័យ៕

# ជំនួបអន្តរសាសនាដើម្បីសុខសន្តិភាពក្នុងសង្គម

*អត្ថបទ៖ សួន ស្រីហួច ដាលីស*



តំណាងសាសនា នៅក្នុងប្រទេសកម្ពុជា បានចូលរួមសិក្ខាសាលាដឹកនាំដោយក្រសួងធម្មការ និងសាសនា ក្រោមប្រធានបទ «សាសនិករួមគ្នាបង្កើនការអភិវឌ្ឍន៍ជាតិ កិច្ចគាំពារសុខសន្តិភាព និងសេរីភាពខាងជំនឿសាសនា» ដែលមានអ្នកចូលរួម៤៥៣នាក់ នៅទីស្តីការក្រសួងធម្មការ និងសាសនា រាជធានីភ្នំពេញកាលពីថ្ងៃទី២១ មិថុនា។

ក្នុងសិក្ខាសាលានេះ មានវាគ្មិនចំនួន៨រូប ពីស្ថាប័ននានាបានលើកឡើងអំពីប្រវត្តិរបស់សាសនានៅប្រទេសកម្ពុជា ភាពខុសគ្នារវាងសាសនានិងសាសនា ការចូលរួមដោយមិនប្រកាន់សាសនា ការថែរក្សាសុខដុមនីយកម្មសាសនា ជាដើម។

លោក ដួង សារ៉ង់ តំណាងព្រះសហគមន៍កាតូលិកកម្ពុជានិយាយថា «សិក្ខាសាលាថ្ងៃនេះរំឭកយើងឱ្យយល់អំពីតម្លៃសន្តិភាព ដែលអាចអភិវឌ្ឍសង្គមជាតិ ជាពិសេសនាំឱ្យសង្គមនៃសាសនាអាចបន្តទៅមុខទៀតបានដោយសុខសន្តិភាព។»

លោកបញ្ជាក់ទៀតថា សិក្ខាសាលានេះជួយឱ្យយើងកុំភ្លេចខ្លួន ដើម្បីឱ្យសាសនាទាំងអស់នៅតែមានវត្តមាន និងសង្គមរបស់យើងនៅស្ថិតស្ថេរ។ ដូច្នេះសូមយើងទាំងអស់គ្នាយកចិត្តទុកដាក់អំពីការកសាងសន្តិភាព។

មុនពេលបិទបញ្ចប់អង្គសិក្ខាសាលានាថ្ងៃនោះ តំណាងសាសនានីមួយៗបានធ្វើសេចក្តីសម្រេចរួមមួយ ដែលមាន៥ចំណុចសំខាន់ៗ គឺ៖ ដឹងគុណដល់សម្តេចហ៊ុនសែន ដែលបានរក្សាសន្តិភាពនិងអភិវឌ្ឍ រក្សាបានសុខដុមនីយកម្មគ្រប់សាសនា, គោរពកិច្ចសហប្រតិបត្តិការសាសនា បង្កើតសាមគ្គីភាពស្មោះត្រង់ដោយឈរលើគោលការណ៍យោគយល់ អធ្យាស្រ័យ គ្រប់កាលៈទេសៈ, គោរពនិងអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល។ គោរពនិងប្រណិប័តន៍វិន័យសាសនារបស់ខ្លួន ដោយគោរពសិទ្ធិអ្នកកាន់សាសនាដទៃ និងគោរពនិងថែរក្សាឲ្យបាននូវប្រពៃណី វប្បធម៌និងទំនាមទម្លាប់ ដែលជាអត្តសញ្ញាណជាតិ ហើយរួមចំណែកអភិវឌ្ឍសង្គម និងជីវភាពរស់នៅរបស់ប្រជាជន។

តាមប្រសាសន៍របស់ព្រឹទ្ធាចារ្យ សារ៉ង់ បានឱ្យដឹងទៀតថា សេចក្តីថ្លែងការណ៍សម្រេចនៅក្នុងថ្ងៃនេះ តាមពិតព្រះសហគមន៍កាតូលិកបាននិងកំពុងអនុវត្តរួចទៅហើយនិង យើងត្រូវចាប់អារម្មណ៍ដើម្បីបន្តអនុវត្តបន្តទៅមុខទៅទៀត។

លោកថា គ្រប់ចំណុចទាំងនោះត្រូវតែយកតែអនុវត្តគឺ ឱ្យយើងយកចិត្តទុកដាក់អំពីសាសនានិមួយៗ និងអប់រំសាសនិក តាមគោលការណ៍សាសនារៀងៗខ្លួននិងបន្ត យកចិត្តទុកដាក់អំពីបញ្ហាសង្គមតាមរយៈការរស់នៅប្រចាំថ្ងៃ ព្រោះសាសនា និងសង្គមត្រូវតែមានទំនាក់ទំនងជាមួយគ្នា។

នៅក្នុងប្រទេសកម្ពុជាដែលមានប្រជាជនសរុបជិត១៦លាននាក់ មានសាសនាធំៗចំនួន៤គឺ ព្រះពុទ្ធសាសនាថេរវាទី មានបរិស័ទប្រមាណ ៩៣% ឥស្លាមសាសនាមានចចំនួន៣,៣៦ % គ្រីស្តសាសនា០,៦៩% ព្រះពុទ្ធសាសនាមហាយាន០,១៤% រួមនិងសាសនាឯទៀតចំនួនប្រមាណជិត១%៕

# សន្តអាសនៈ បន្តជំរុញឱ្យការពារ សេចក្តីថ្លៃថ្នូរជនឥន្តោប្រវេសន៍

*អត្ថបទ៖ នរិន្ទបុត្រ*

លោក ចន ភុតហ្ស៊ែ (John Putzer) អ្នកការទូតសន្តអាសនៈបានបន្តលើកឡើងអំពីតម្រូវការនៃសាមគ្គីភាពជាអន្តរជាតិ ដើម្បីការពារសេចក្តីថ្លៃថ្នូរ របស់ក្រុមជនឥន្តោប្រវេសន៍។ នេះបើតាមសេចក្តីរាយការណ៍របស់វ៉ាទីកង់ញូវ។



លោក ចន ភុតហ្ស៊ែ បានថ្លែងបែបនេះទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សនាទីក្រុងហ្សឺណែវ ប្រទេសស្វីស។ លោក ចន ភុតហ្ស៊ែរ បានស្នើសុំឲ្យរដ្ឋសមាជិកទាំងអស់នៃក្រុនប្រឹក្សាសិទ្ធិមនុស្សរួបរួមសាមគ្គីគ្នា និងបន្តប្រយុទ្ធប្រឆាំងដើម្បីការពារសិទ្ធិ របស់ក្រុមជនឥន្តោប្រវេសន៍ ខណៈដែលពួកគេកំពុងតែស្វះស្វែងរកជីវភាពមួយដែលប្រសើរជាងពីមុន។

លោកក៏បានចែករំលែកនូវសេចក្តីព្រួយបារម្ភ និងតម្រូវការសុវត្ថិភាពបន្ថែមទៀតចំពោះក្រុមជន ឥន្តោប្រវេសន៍ដែលបានបន្តរងគ្រោះដោយសារតែការប៉ុនប៉ងចំណាកស្រុកគេចពីសង្គ្រាម និងជម្លោះប្រដាប់អាវុធគ្រប់ប្រភេទ។

លោកបានបន្តថា ពួកគេដែលជាជនភៀសខ្លួនបានជួបនូវទុក្ខសោកសង្រេងកាត់ថ្លៃមិនបានទៅ ហើយនៅស្រុកកំណើតពួកគេ ដូច្នេះការគាំពារ និងលើកទឹកចិត្តគឺជាកិច្ចការដ៏សំខាន់ ដែលគ្រប់គ្នាត្រូវតែយកចិត្តទុកដាក់ចំពោះពួកគេ៕

## សម្តេចប៉ាបថ្លែងអំណរគុណចំពោះទីភ្នាក់ងារជំនួយអាមេរិកឡាទិន

*សម្រួលដោយ៖ នរិន្ទបុត្រ*

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូបានថ្លែងអំណរគុណជាពិសេសទៅកាន់អស់ទីភ្នាក់ងារជំនួយនានានៅអាមេរិកឡាទីន ដែលពួកគេមិនដែលភ្លេច ឬបោះបង់សកម្មភាពមនុស្សធម៌នៅក្រោមអត្តសញ្ញាណជាគ្រីស្តបរិស័ទ។

សារដ៏មានអត្ថន័យនេះ ត្រូវបានផ្ញើដោយសម្តេចប៉ាបតាមរយៈសារមួយច្បាប់ដែលទ្រង់បានផ្ញើរទៅកាន់កិច្ចប្រជុំរបស់ក្រុមបណ្តាញអង្គការសង្គមស៊ីវិល និងស្ថាប័នជំនួយរបស់គ្រីស្តបរិស័ទ នៅតំបន់អាមេរិកឡាទិនដែលបានជួបជុំគ្នានៅក្នុងវ៉ាទីកង់កាលពីចុងសប្តាហ៍មុន។

នាឱកាសនោះ សម្តេចប៉ាបបានមានបន្ទូលរំលឹកពួកគេ និងវាយតម្លៃខ្ពស់ចំពោះការងារមនុស្សធម៌ ដែលពួកគេបានបំពេញកន្លងមក នៅក្នុងនាមជាអង្គការមនុស្សធម៌នៅក្នុងតំបន់។

សម្តេចប៉ាបមានបន្ទូលថា អាមេរិកឡាទីនជាតំបន់ដែលកំពុងតម្រូវឲ្យមានសាមគ្គីភាព ប្រកបដោយទស្សនៈវិជ្ជមានចំពោះទីតាំងភូមិសាស្ត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ជនក្រីក្របំផុត និងត្រូវបានគេមិនសូវរវីរវល់បំផុតនៅក្នុងសង្គម។

សម្តេចប៉ាបបានមានបន្ទូលថា កិច្ចការមួយក្នុងចំណោមកិច្ចការរបស់បណ្តាស្ថាប័នទាំងនោះ គឺការគាំទ្រហិរញ្ញវត្ថុដល់គម្រោងការផ្សព្វផ្សាយ និងដោះស្រាយស្ថានភាពបន្ទាន់ និងលើកកម្ពស់សកម្មភាពសំខាន់ៗ សម្រាប់ព្រះសហគមន៍នៅក្នុងតំបន់ពង្រឹងសមត្ថភាព និងបេសកម្មមនុស្សធម៌របស់ពួកគេ៕

# សម្តេចប៉ាប បានបញ្ជូន បេសកជនពិសេស ទៅកាន់ប្រទេសរុស្ស៊ី

*សម្រួលដោយ៖ នរិន្ទបុត្រ*

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានកំពុងតែបញ្ជូនលោក កាឌីណាល់ ម៉ាតេអូ ម៉ារៀ ហ្សូពី (Matteo Maria Zuppi ) នៅក្នុងនាមជាបេសកជនរបស់ទ្រង់ទៅកាន់ប្រទេសរុស្ស៊ី ដើម្បីជំរុញឲ្យមានកិច្ចសន្ទនា និងស្វែ ងរកដំណោះស្រាយសន្តិភាពនៅក្នុងសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ។

វ៉ាទីកង់ញូវបានរាយការណ៍ថា លោកកាឌីណាល់នឹងបំពេញមុខងារនៅក្នុងនាមជាបេសកជនពិសេសសម្តេចប៉ាបរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី ២៨ ដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដើម្បីពង្រឹង និងពិនិត្យមើ លលទ្ធភាព ឬប្រកដែលអាចនឹងផ្តល់វិភាគទានដល់ការជំរុញរកដំណោះស្រាយឆ្លើយតបនឹងគ្រោះមហន្តរាយដែលកើតមានឡើងដោយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន។

លោកកាឌីណាល់ នឹងធ្វើកិច្ចការទាំងនេះរួមជាមួយនឹងមន្ត្រីនៃក្រសួងការបរទេសរបស់សន្តអាសនរហើយគ្រោងនឹងបន្តបង្ហាញនូវសុឆន្ទនិងបំណងរបស់សម្តេចប៉ាបទាក់ទងនឹងបញ្ហាសន្តិភាពតាមមធ្យោបាយសន្តិភាព ។

គួររំលឹកដែរថា កាលពីថ្ងៃទី៥ ដល់៦ ខែមិថុនា កន្លងទៅនេះ លោកកាឌីណាល់បានជួបមន្ត្រីអ៊ុយក្រែន ជាច្រើនរូបដោយរួមទាំងប្រធានាធិបតី វ្លូឡូទីមៀរ ហ្សាឡេនស្គី ផងដែរ៕



# អគ្គសញ្ញាលាបថ្ងាស នៅព្រៃកពោធិ៍







*សម្រួលដោយ៖ នរិន្ទបុត្រ*

ថ្ងៃអាទិត្យទី៩ ខែកក្កដា ឆ្នាំ២០២៣ ត្រូវនឹងថ្ងៃអាទិត្យទី១៤ ក្នុងរដូវធម្មតា លោកអភិបាលសិលា សួន ហង្សលី អភិបាលនៃព្រះសហគមន៍ភូមិភាគកំពង់ចាមបានអញ្ជើញប្រារព្ធពិធីអគ្គសញ្ញាលាបថ្ងាសឲ្យបេក្ខជន បេក្ខនារីចំនួនប្រាំនាក់នៅព្រះសហគមន៍ព្រៃកពោធិ៍ព្រះមាតានៃសន្តិភាព ស្ថិតនៅភូមិរកាទ្វារ ឃុំព្រៃកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

អគ្គលាបថ្ងាស ជាអគ្គសញ្ញាមួយក្នុងចំណោមអគ្គសញ្ញា៧របស់ព្រះសហគមន៍កាតូលិក។ ពិធីនេះធ្វើឡើងដោយលោកអភិបាលព្រះសហគមន៍ ដើម្បីចាត់គ្រីស្តបរិស័ទឲ្យចេញទៅប្រកាសដំណឹងល្អ ដូចគ្រីស្តទូតពីដើម ដែលបានបើកទ្វារចេញទៅប្រកាសពីព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ក្រោយពេលពួកគេទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។

តាមគោលទិ្ធរបស់ព្រះសហគមន៍ឱ្យដឹងថា អំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធមានចំនួន៧គឺ ព្រះវិញ្ញាណដែលផ្តល់ប្រាជ្ញាញាណ ព្រះវិញ្ញាណដែលផ្តល់ឲ្យចេះពិចារណាដឹងខុសដឹងត្រូវ ព្រះវិញ្ញាណដែលផ្តល់ឲ្យមានយោបល់ល្អ ព្រះវិញ្ញាណដែលផ្តល់ឲ្យស្គាល់សេចក្តីពិត ព្រះវិញ្ញាណដែលផ្តល់ឲ្យមានចិត្តអង់អាច ព្រះវិញ្ញាណដែលផ្តល់ឲ្យចេះគោរពប្រណិប័តន៍ព្រះបិតា និងព្រះវិញ្ញាណដែលបំភ្លឺឲ្យចេះគោរពកោតខ្លាចព្រះជាម្ចាស់។

តាំងពីបុណ្យព្រះវិញ្ញាណយាងមកកាលពីខែឧសភាកន្លងទៅរហូតមកដល់ពេលនេះ មានអ្នកទទួលអគ្គសញ្ញាលាបថ្ងាសក្នុងភូមិភាគកំពង់ចាម ចំនួន២៦នាក់៕

# សកម្មភាពនានារបស់ព្រះសហគមន៍កាតូលិកកម្ពុជា

## ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម



## ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង



## ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ







